**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០៣/០៧-០៩-២០០៩-អវតក/កសចស (អ.ប.ជ៣៨) |
| **ដាក់ទៅ** | : | អង្គបុរេជំនុំជម្រះ |
| **ថ្ងៃដាក់** | : | ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២១ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| **ភាសាដើម** | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 15-Jul-21, 14:57
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** **សាធារណៈ**

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គបុរេជំនុំជម្រះ:** សាធារណៈ/Public

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ មាស មុត សុំឲ្យបញ្ចប់នីតិវិធីបោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ**

---

**អ្នកដាក់ឯកសារ:**

លោកស្រី Brenda J. HOLLIS

**សហព្រះរាជអាជ្ញាអន្តរជាតិ**

**ចម្លងជូន:**

លោកស្រី ជា លាង

**សហព្រះរាជអាជ្ញាជាតិ**

**អ្នកទទួលឯកសារ:**

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គឹមសាន, ប្រធាន

ចៅក្រម Olivier BEAUVALLET

ចៅក្រម ន័យ ថុល

ចៅក្រម Kang Jin BAIK

ចៅក្រម ហួត វុទ្ធី

**សហមេធាវី មាស មុត:**

លោក អាង ឧត្តម

លោក Michael KARNAVAS

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

**ក្នុងសំណុំរឿង ០០៣**

# I. សេចក្តីផ្តើម

1. ការបញ្ចប់នីតិវិធី ការបោះត្រា និងការដាក់បញ្ចូលក្នុងបណ្ណសារនូវសំណុំរឿង ០០៣ ដោយពុំមានការជំនុំជម្រះចំពោះបទចោទដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[1] គឺជាការបដិសេធនូវយុត្តិធម៌ចំពោះភាគី*ទាំងអស់* ជនរងគ្រោះដែលនៅរស់និងដែលបានស្លាប់ និងប្រជាពលរដ្ឋកម្ពុជាជាទូទៅ។ ទោះបីសហព្រះរាជអាជ្ញាអន្តរជាតិ("ស.ព.ស") យល់ស្របថា ជាការសមស្របដែលអង្គបុរេជំនុំជម្រះ ("អ.ប.ជ") ទទួលយកសំណើរបស់ មាស មុត[2]ក៏ដោយ ក៏វានៅតែមិនសមស្របជាផ្ទៃក្នុង និងពោរពេញទៅដោយកំហុសអង្គហេតុ អង្គច្បាប់ និងតក្កវិជ្ជា ដែលគួរតែត្រូវបានច្រានចោល។

2. ស.ព.អ យល់ស្របថា "វាដល់ពេលដែល អ.ប.ជ ត្រូវបំពេញកិច្ចជាស្ថាពរ" និងថា បើសិនជា អ.ប.ជ ខកខានមិនបានបំពេញកិច្ចដូច្នេះ "វាគឺជាការបោះបង់ចោលនូវការទទួលខុសត្រូវ[របស់ខ្លួន]"[3]។ យ៉ាងណាមិញ ផ្ទុយពីសំណើសុំបញ្ចប់នីតិវិធីរបស់ មាស មុត ការបំពេញកិច្ចជាស្ថាពរដែលតម្រូវ គឺជាការបញ្ជូនសំណុំរឿងនេះទៅជំនុំជម្រះដោយគ្មានការពន្យារពេល។ នេះគឺជាលទ្ធផលតែមួយគត់ដែលស្របនឹងក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក និងការសម្រេចជាឯកច្ឆន្ទរបស់អង្គជំនុំជម្រះនេះ ដែលថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព[4]។ ជាការពិត ចំណុចទាំងពីរនេះដាក់អាណត្តិឱ្យការទទួលខុសត្រូវរបស់ មាស មុត ចំពោះឧក្រិដ្ឋកម្មនានាដែលជនរងគ្រោះ និងសហគមន៍សកលលោកស្អប់ខ្ពើមបំផុត ត្រូវបានសម្រេចដោយដំណើរការតាមផ្លូវតុលាការដែលត្រឹមត្រូវយុត្តិធម៌ និងអនាគតិ ដែលបំរើដល់ផលប្រយោជន៍នៃយុត្តិធម៌សម្រាប់គ្រប់ភាគី*ទាំងអស់*[5]។

---

[1] ឯកសារ **D267** ដីកាដំណោះស្រាយ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ")។

[2] ឯកសារ **D272** សំណើរបស់ មាស មុត សុំបញ្ចប់ បោះត្រា និង ដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១ ("សំណើសុំបញ្ចប់")។

[3] ឯកសារ **D272** សំណើសុំបញ្ចប់, កថាខណ្ឌ ៧៣។

[4] ឯកសារ **D266/27 & D267/35** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១ ("សេចក្តីពិចារណា") មតិយោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ផុល និងចៅក្រម ហួត វុទ្ធី កថាខណ្ឌ ១១៥ បានអនុមតិដោយចៅក្រមជាតិទាំងបីរូប តាមរយៈការចុះហត្ថលេខារបស់ចៅក្រមទាំងបីនៅត្រង់ អង់គ្លេស 01666986, បារាំង 01667144, ខ្មែរ 01667332។ មតិយោបល់របស់ចៅក្រម Olivier Beauvallet និង Kang Jin Baik ("មតិយោបល់របស់ចៅក្រមអន្តរជាតិ"), កថាខណ្ឌ ១១៩, ២៦២, ២៨៤, ៣៣៩-៣៤០, ៣៤២-៣៤៣ បានអនុមតិដោយចៅក្រមអន្តរជាតិទាំងពីររូប តាមរយៈការចុះហត្ថលេខារបស់ចៅក្រមទាំងពីរត្រង់ អង់គ្លេស 01667089, បារាំង 01667264, ខ្មែរ 01667480។

[5] ឯកសារ **D271/1** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យបិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០៣ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១។ ស.ព.អ បង្រួមបញ្ចូលគ្នានូវសេចក្តីយោងនៃសំណើសុំបញ្ចប់នេះ។

## II. សារណា

3. ជាកិច្ចការមួយមិនទាន់មកដល់ តែ ស.ព.អ កត់សំគាល់ឃើញអំពីភាពមិនស្របគ្នាផ្ទៃក្នុងផង និងភាពផ្ទុយគ្នាផងនៃសំណើសុំនេះ ដែលមិនគួរត្រឹមតែទទួលបានការទាត់ចោលប៉ុណ្ណោះទេ គឺថែមទាំងសមនឹងទទួលបានការបដិសេធដោយសង្ខេបទៀតផង[6]។ និយាយអំពីភាពផ្ទុយគ្នា គឺ មាស មុត តវ៉ាឱ្យបញ្ចប់នីតិវិធីជាបន្ទាន់ និងដោយគ្មានលក្ខខណ្ឌ[7] ហើយក្នុងពេលជាមួយគ្នាគាត់បញ្ជាក់មិនតិចជាងបីដង យ៉ាងច្បាស់ថា គាត់ស្នើឱ្យបដិសេធសំណុំរឿង ០០៣ *លើកលែងតែ* អ.ប.ជ ពេលនេះមិនអាចរកសំឡេងភាគច្រើនលើសលុបដើម្បីបញ្ជូនរឿងក្តីទៅជំនុំជម្រះតែប៉ុណ្ណោះ[8]។ ជាការពិត ទោះបីជាពេលនេះគាត់

---

[6] អង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") បានសម្រេចថា អង្គជំនុំជម្រះ "មិនអាចតម្រូវឱ្យពិចារណាសារណារបស់ភាគីជាលម្អិតនោះទេ ប្រសិនបើសារណាទាំងនោះមានលក្ខណៈមិនច្បាស់លាស់ មានលក្ខណៈផ្ទុយ [ឬ]មានលក្ខណៈស្រពេចស្រពិល"។ *សូមមើល* សំណុំរឿង ០០២-ឯកសារ **F36** សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ១០១ *យោង* សំណុំរឿង ០០១-ឯកសារ **F28** សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ("សាលដីកា ឌុច") កថាខណ្ឌ ២០។ អ.ប.ជ បានប្រើអភិក្រមដូចគ្នា។ *សូមមើល ឧទាហរណ៍* សំណុំរឿង ០០២-ឯកសារ **D300/2/2** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស ស្តីពីសំណើសុំលេខ D153, D172, D173, D174, D178 និង D284 ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១០, កថាខណ្ឌ ១៩-២០។ *សូមមើល ផងដែរ* ឯកសារ **D266/27 & D267/35** សេចក្តីពិចារណា មតិយោបល់របស់ចៅក្រមអន្តរជាតិ, កថាខណ្ឌ ១៩០-១៩១ (សារណា "មិនអាចត្រូវបានអនុញ្ញាតឱ្យបង្វែរទៅជាការទាយស្មានសម្រាប់អង្គបុរេជំនុំជម្រះឡើយ")។

[7] ឯកសារ **D272** សំណើសុំបញ្ចប់, ទំព័រ ១, ៣០។

[8] ឯកសារ **D272** សំណើសុំបញ្ចប់, កថាខណ្ឌ ៤៧ (*"ប្រសិនបើ អ.ប.ជ គ្មានលទ្ធភាពសម្រេចបានសំឡេងភាគច្រើនលើសលុបក្នុងការបញ្ជូនលោក មាស មុត ទៅជំនុំជម្រះទេ* នោះ អ.ប.ជ ត្រូវបញ្ចប់រឿងក្តី ០០៣ បោះត្រា និងដាក់បញ្ចូលសំណុំរឿងទៅក្នុងបណ្ណសារ។ *ទោះតាមវិធីណាមួយក៏ដោយ* អ.ប.ជ ត្រូវបំពេញកិច្ចនេះយ៉ាងប្រាកដប្រជា និងឱ្យបានឆាប់រហ័ស" (ន័យដើមត្រូវបានលុប) (សង្កត់ន័យដើម))។ ត្រង់ចំណងជើង III.ឃ ("អ.ប.ជ ត្រូវតែបញ្ចប់ បោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ វៀរលែងតែ អ.ប.ជ បង្វែរ និងសម្រេចដោយសំឡេងភាគច្រើនលើសលុប ដើម្បីបញ្ជូនរឿងក្តី ០០៣ ទៅជំនុំជម្រះ" (សង្កត់ន័យដើម)), កថាខណ្ឌ ៧៣ (*"ប្រសិនបើ ចៅក្រមនៃ អ.ប.ជ មិនមានសមត្ថភាពក្នុងការចេញសេចក្តីសម្រេចតាមសំឡេងភាគច្រើនលើសលុប ក្នុងការបញ្ជូនរឿងក្តី ០០៣ ទៅជំនុំជម្រះទេ* នោះ អ.ប.ជ ត្រូវតែប្រកាន់ខ្ជាប់ទៅតាមសម្បថតាមផ្លូវតុលាការរបស់ខ្លួន និងគោរពតាមច្បាប់យ៉ាងស្មោះត្រង់ ដោយអនុវត្តសិទ្ធិអំណាចរបស់ខ្លួន ក្នុងការបញ្ចប់ដំណើរការនីតិវិធី បោះត្រាសំណុំរឿង រួចដាក់បញ្ចូលវាទៅក្នុងបណ្ណសារ") (ន័យដើមត្រូវបានលុប) (សង្កត់ន័យដើម))។ *សូមមើល ផងដែរ* កថាខណ្ឌ ៦០ (*"ប្រសិនបើ អ.ប.ជ មិនអាចស្រុះស្រួលគ្នាលើមតិទូទៅ ឬ ឥតមានសំឡេងភាគច្រើនលើសលុប និងមិនអាចចេញសេចក្តីសម្រេចដែលស្ថាពរ និងដែលចងកាតព្វកិច្ច ក្នុងការបញ្ចប់ដំណើរការនីតិវិធីមុនជំនុំជម្រះនៃរឿងក្តី ០០៣ ដោយបំពេញកាតព្វកិច្ចដ៏សំខាន់របស់ខ្លួន ដើម្បីធានាសិទ្ធិរបស់លោក មាស មុត ក្នុងការទទួលបានការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិ*

ហាក់ដូចជាទាត់ចោលការពិតអំពីរឿងនេះក្ដី ក៏មិនមានចំណុចណាមួយនៃសំណើ*នេះ* បញ្ជាក់ថា មាស មុត បដិសេធការសម្រេចជាឯកច្ឆន្ទរបស់ អ.ប.ជ ដែលថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ មានសុពលភាពនោះដែរ។ ផ្ទុយទៅវិញ គាត់រៀបរាប់អំពីការសម្រេចរបស់ចៅក្រម អ.ប.ជ ទាំងប្រាំរូបដែលមានអនុភាព[9]។ គាត់អះអាងថាគាត់ស្វែងរកចម្លើយតែមួយទេគឺថា"តើគាត់នឹងប្រឈមមុខនឹងការជំនុំជម្រះដែរឬអត់ តែប៉ុណ្ណោះ"[10] ដែលសំដែងឲ្យឃើញអំពីសំណើសុំម្ដងហើយម្ដងទៀតរបស់គាត់ទាំងនៅក្នុងសំណើសុំលើកនេះ[11] និងសំណើសុំពីមុនៗ[12] ដើម្បីមានឱកាសតវ៉ាចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ គោលជំហររបស់ មាស មុត មិនត្រឹមតែផ្ទុយគ្នាប៉ុណ្ណោះទេ ប៉ុន្តែការសុខចិត្តទទួលយកការជំនុំជម្រះដែលអនុមតិដោយសំឡេងភាគច្រើនលើសលុបរបស់ អ.ប.ជ ធ្វើឲ្យខូចដល់អំណះអំណាងរបស់គាត់ទាំងមូលទាក់ទងនឹងការបញ្ចប់សំណុំរឿង ០០៣ ជាបន្ទាន់ ដោយគ្មានការពន្យារពេលត្រឹមត្រូវ[13]។

*ពុំមានការពន្យារពេលមិនត្រឹមត្រូវក្នុងសំណុំរឿង ០០៣ ទេ*

4. អំណះអំណាងរបស់ មាស មុត ថាកិច្ចដំណើរការនីតិវិធីនានាមានការរំលោភលើសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌ និយាយឲ្យចំគឺសិទ្ធិទទួលបាននូវកិច្ចដំណើរការនីតិវិធីឆាប់រហ័ស

---

*ធម៌ទេ នោះ អ.ប.ជ ត្រូវបញ្ចប់ដំណើរការនីតិវិធីក្នុងរឿងក្ដី ០០៣ នេះ ដោះត្រា និងដាក់បញ្ចូលសំណុំរឿងទៅក្នុងបណ្ណសារ ដើម្បីជៀសពីការរំលោភលើនីតិវិធី និងការថ្កោះថ្កោយលើភាពអយុត្តិធម៌"* (សង្កត់ន័យដើម))។

[9] ឯកសារ **D272** សំណើសុំបញ្ចប់, កថាខណ្ឌ ៣២, ៣៤។

[10] ឯកសារ **D272** សំណើសុំបញ្ចប់, កថាខណ្ឌ ៥៤។

[11] ឯកសារ **D272** សំណើសុំបញ្ចប់, កថាខណ្ឌ ៥៤, ៧១។

[12] *សូមមើល ឧទាហរណ៍* ឯកសារ **D267/27** សារណាបន្ថែមរបស់ មាស មុត ទៅលើបណ្ដឹងឧទ្ធរណ៍របស់ខ្លួន ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២០ ទំព័រ១, កថាខណ្ឌ ២៤, ៥០។ ឯកសារ **D249/2** សារណារបស់ មាស មុត ស្ដីពីស្ថានភាពថវិការបស់ អ.វ.ត.ក. និង ផលប៉ះពាល់លើរឿងក្ដី ០០៣ ចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៧ ("សារណារបស់ មាស មុត ស្ដីពីថវិកា") កថាខណ្ឌ ២៨-២៩។ ឯកសារ **D267/4** បណ្ដឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩ ទំព័រ១, កថាខណ្ឌ ២, ៤២-៤៣, ៤៧។ ឯកសារ **D267/31** ការឆ្លើយតបរបស់របស់ មាស មុត ទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិតបទៅនឹងសារណាបន្ថែមរបស់ មាស មុត ទៅលើបណ្ដឹងឧទ្ធរណ៍របស់ខ្លួនជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០, កថាខណ្ឌ ៤, ២២។ ឯកសារ **D256/11** ចម្លើយរបស់ មាស មុត តបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨, កថាខណ្ឌ ១៩, ៦៧។

[13] ឯកសារ **D272** សំណើសុំបញ្ចប់, ទំព័រ ១, ៣០, កថាខណ្ឌ ៥១-៦៩។

នោះ[14]គឺពុំមានមូលដ្ឋានទេ។ ជាការមិនស្របគ្នាដែរ សូម្បីតែ មាស មុត ខ្លួនឯងក៏ទទួលស្គាល់ថា ដើម្បីសម្រេចបាននូវយុត្តិធម៌មួយដែលត្រឹមត្រូវ មានលក្ខណៈតទល់គ្នានិងជាអន្តរជាតិ គេត្រូវការពេលវេលាច្រើនគួរសម ដូចដែលគាត់បានទទួលស្គាល់ក្នុងឆ្នាំ២០១៧ យ៉ាងដូច្នេះថា៖

សូម្បីតែសិស្សស្ទើរៗពីសម័យកម្ពុជាប្រជាធិបតេយ្យ ដែលដឹងតិចតួចអំពីការកាត់សេចក្តីអំពើឃោរឃៅជាទ្រង់ទ្រាយធំ មិនទាន់មានប្រាជ្ញាញាណក៏អាចមើលឃើញថា ការកាត់សេចក្តីតែរឿងក្តីមួយក៏ត្រូវការចំណាយពេល ៣ឆ្នាំ ទៅ ៥ឆ្នាំដែរ។ នៅពេលពិចារណានៅក្នុងដំណាក់កាលបុរេជំនុំជម្រះ និងបណ្តឹងសាទុក្ខ ដែលដូចគ្នានឹងអ្នករៀនស្ទើរនេះ ក៏គេអាចដឹងថា រឿងក្តីមួយអាចចំណាយពេលពី ៥ឆ្នាំ ទៅ ១២ឆ្នាំដែរ ពីដើមដល់ចប់។ [...] វាមិនពិបាកយល់ក្នុងការគិតថា អ្នកតំណាង អ.ស.ប ក្នុងការបង្កើត អ.វ.ត.ក មិនបានដឹងថាសាលាក្តីនេះមានចិរវេលាជា*អប្បបរមា* ពី១៤ ទៅ ១៨ឆ្នាំ[...]។ ដោយពិចារណាអំពីទម្រង់ដែល អ.ស.ប និងរដ្ឋាភិបាលកម្ពុជាបានព្រមព្រៀង យុត្តិធម៌ផ្នែកនីតិវិធី និងជាសារធាតុនៅ អ.វ.ត.ក តែងតែត្រូវចំណាយពេលច្រើនលើស [...][15]។

5. ដោយទុកភាពផ្ទុយគ្នានេះមួយអន្លើ ការចោទប្រកាន់របស់ មាស មុត នៅពេលនេះអំពីការរំលោភសិទ្ធិរបស់គាត់ក្នុងការទទួលបានកិច្ចដំណើរការនីតិវិធីឆាប់រហ័ស គឺគ្មានមូលដ្ឋានទេ សម្រាប់មូលហេតុដូចបានគូសបញ្ជាក់ខាងក្រោម។

6. មាស មុត បន្ថែមពេលវេលាស្ទើរតែបួនឆ្នាំដើម្បីតវ៉ាក្នុងបញ្ហានៃកិច្ចដំណើរការនីតិវិធី ដែលបានធ្វើឱ្យមានការពន្យារពេលមិនត្រឹមត្រូវ។ ដូចគាត់ខ្លួនឯងបានចង្អុលបង្ហាញ[16] ចំណុចចាប់ផ្តើមសម្រាប់ការកំណត់ថាតើកិច្ចដំណើរការនីតិវិធីនានាត្រូវបានធ្វើឡើងក្នុងពេលវេលាមួយសមស្របដែរឬអត់ គឺចាប់ពីពេលដែលគាត់ "ត្រូវបានជូនដំណឹងជាផ្លូវការថា គាត់នឹងត្រូវបានចោទប្រកាន់" មានន័យថា ចាប់ពីពេលដែលអាជ្ញាធរមានសមត្ថកិច្ចបានជូនដំណឹងគាត់អំពីការចោទប្រកាន់ថា គាត់បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ[17]។ ការនេះបានកើតឡើងចំពោះ មាស មុត នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ គឺនៅពេល

---

[14] ឯកសារ **D272** សំណើសុំបញ្ចប់, កថាខណ្ឌ ៤៧-៥៩, ៧០។

[15] ឯកសារ **D249/2** សារណារបស់ មាស មុត ស្តីពីចរិកា, កថាខណ្ឌ ២-៣ (សង្កត់ន័យដើម)។

[16] ឯកសារ **D272** សំណើសុំបញ្ចប់, កថាខណ្ឌ ៥៩។

[17] ឯកសារ **D120/3/1/8** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងដីកាសម្រេចចេញសាឡើងវិញរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើញត្តិរបស់ មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ, មតិយោបល់របស់ចៅក្រម Beauvallet និង Baik ("ចៅក្រមដែលបានចុះហត្ថលេខាខាងក្រោម")

ដែលសហចៅក្រមស៊ើបអង្កេតបម្រុង ("ស.ច.ស") Laurent Kasper-Ansermet បានជូនដំណឹងគាត់ថា គាត់ជាជនសង្ស័យម្នាក់នៅក្នុងកិច្ចស៊ើបសួរដែលកំពុងធ្វើឡើង[18]។ ដូច្នេះ ថិរវេលាពាក់ព័ន្ធគឺទើបតែប្រាំបួនឆ្នាំ មិនមែន ១៣ឆ្នាំទេ[19]។

7. មាស មុត ខកខានមិនបានបំពេញឲ្យឃើញថា[20]សិទ្ធិក្នុងការទទួលបានកិច្ចដំណើរការនីតិវិធីឆាប់រហ័សរបស់គាត់ មិនពឹងផ្អែកទៅលើតែចំនួនពេលវេលាដែលកន្លងផុត[21] ឬការពន្យារពេលណាមួយឡើយ[22]។

---

ទាក់ទងនឹងអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ ("សេចក្តីពិចារណាលើញត្តិសុំលុបចោលរបស់ចៅក្រមអន្តរជាតិ"), កថាខណ្ឌ ៣៥ ជើងទំព័រ ១៣៤ *យោង* រឿងក្តី *Eckle ទល់នឹង ប្រទេសអាល្លឺម៉ង់* លេខ 8130/78, សាលក្រម ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៨២ កថាខណ្ឌ ៧៣។ រឿងក្តី *Hozee ទល់នឹង ប្រទេសហូឡង់* លេខ 21961/93, សាលក្រម ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៩៨ កថាខណ្ឌ ៤៣។ រឿងក្តី *Coëme និងអ្នកផ្សេងទៀត ទល់នឹង ប្រទេសបែលហ្ស៊ិក* លេខ 32492/96, 32547/96, 32548/96, 33209/96, 33210/96, សាលក្រម ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០០ ("សាលក្រមរឿងក្តី *Coëme ទល់នឹង ប្រទេសបែលហ្ស៊ិក*") កថាខណ្ឌ ១៣៣។

[18] ឯកសារ **D30** ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ [វិធាន ២១.១ឃ] ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២។ មាស មុត ធ្លាប់អះអាងពីមុនថា គាត់បានដឹងថា គាត់ត្រូវបានដាក់ឲ្យស្ថិតក្រោមកិច្ចស៊ើបសួរតាមផ្លូវតុលាការនៅក្នុងឆ្នាំ២០១១ គឺនៅពេលដែលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមសម្ងាត់ បានលេចធ្លាយដល់សារព័ត៌មាន (*សូមមើល* ឯកសារ **D249/2** សារណារបស់ មាស មុត ស្តីពីថវិកា, កថាខណ្ឌ២៦)។ ដូចដែលការជូនដំណឹងនេះមិនមែនជាការជូនដំណឹងផ្លូវការដោយអាជ្ញាធរមានសមត្ថកិច្ច វាមិនគ្រប់គ្រាន់ទេដើម្បីចាប់ផ្តើមគិតពីពេលវេលាសម្រាប់គោលបំណងបច្ចុប្បន្ន។

[19] *ផ្ទុយពី* ឯកសារ **D272** សំណើសុំបញ្ចប់, កថាខណ្ឌ ១, ៤៧, ៥១-៥២, ៥៤, ៦៥, ៧០, ចំណងជើង III.ខ។ តុលាការសិទ្ធិមនុស្សអ៊ឺរ៉ុប ("ECtHR") សង្កត់ធ្ងន់លើពេលវេលាដែលជននោះ *បានដឹង* ជាផ្លូវការអំពីកិច្ចដំណើរការនីតិវិធីដែលផ្ទុយពីការដែលគ្រាន់តែបានដឹងអំពីអត្ថិភាពនៃកិច្ចស៊ើបសួរ។ *សូមមើល ឧទាហរណ៍* រឿងក្តី *Ustyantsev ទល់នឹង ប្រទេសអ៊ុយក្រែន* លេខ 3299/05, សាលក្រម ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១២ កថាខណ្ឌ ៩១។ រឿងក្តី *Kechev ទល់នឹង ប្រទេសប៊ុលហ្គារី* លេខ 13364/05, សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២ កថាខណ្ឌ ៤៧។

[20] *សូមមើល ឧទាហរណ៍* ឯកសារ **D272** សំណើសុំបញ្ចប់, កថាខណ្ឌ ៤៧ ("កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងលោក មាស មុត រយៈពេល១៣ឆ្នាំ ទោះតាមការគិតស្រមៃបែបណាក៏ដោយ ក៏មិនសមស្របនឹងសិទ្ធិរបស់គាត់ ក្នុងការទទួលបានដំណើរការនីតិវិធីឆាប់រហ័សនោះដែរ")។ វាក្យខណ្ឌ III.ខ (មានចំណងជើងថា "ការពន្យារពេលរហូតដល់ ១៣ ឆ្នាំ លើដំណើរការនីតិវិធីនៅមុនពេលជំនុំជម្រះរឿងក្តី ០០៣ គឺមិនសមហេតុផលទេ")។

[21] *ឧទាហរណ៍* <u>ICTY</u>: រឿងក្តី *Šešelj*, IT-03-67-T, សេចក្តីសម្រេចលើសំណើសុំផ្ទាល់មាត់របស់ជនជាប់ចោទ អំពីការបំពានដំណើរការ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១០ ("សេចក្តីសម្រេចស្តីពីការបំពានដំណើរការក្នុងរឿងក្តី *Šešelj*") កថាខណ្ឌ ៣០ ("ករណីយុត្តិសាស្ត្រអន្តរជាតិនិងអ៊ឺរ៉ុប បានកំណត់យ៉ាងច្បាស់ថា គ្មានលក្ខខណ្ឌតម្រូវដែលបានកំណត់ទុកជាមុន ទាក់ទងនឹងថិរវេលាដែលលើសធ្វើឲ្យការជំនុំជម្រះអាចនឹងត្រូវបានចាត់ទុកថាមិនយុត្តិធម៌ដោយផ្អែកលើការពន្យារពេលមិនសមរម្យនោះទេ")។ <u>ICTR</u>: រឿងក្តី *Ntabakuze*, ICTR-98-41A-A, សាលក្រម ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១២ កថាខណ្ឌ ២០ ("ប្រវែងនៃការជាប់ឃុំឃាំងរបស់ជនជាប់ចោទ រយៈពេលនេះមិនអាចបង្កើតបានជាការពន្យារពេលដោយមិនសមរម្យឡើយ ហើយការពិត

ផ្ទុយទៅវិញ អត្ថន័យដ៏ងាយយល់នៃវិធាន ២១(៤)[23] នៃវិធានផ្ទៃក្នុង និងមាត្រា ១៤(៣)(គ) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ("ICCPR") ដែលវិធានផ្ទៃក្នុងនេះបានពឹងផ្អែក[24] បានបញ្ជាក់យ៉ាងច្បាស់ថា ថិរវេលានៃកិច្ចដំណើរការនីតិវិធីគឺត្រូវ "សមស្រប" ឬ និយាយម្យ៉ាងទៀតថា *"ដោយពុំ*

---

ដែល Ntabakuze បានជាប់ឃុំរហូតដល់ ១២ ឆ្នាំ មកដល់ពេលដែលគាត់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍របស់គាត់ គឺមិនគ្រប់គ្រាន់ទេបើនិយាយតែរយៈពេលនេះ ដើម្បីបង្ហាញឲ្យឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួនថា មិនមានការពន្យារពេលមិនសមរម្យនៅក្នុងកិច្ចដំណើរការនីតិវិធី")។ រឿងក្តី *Bizimungu និងគូកន,* ICTR-99-50-T, សាលក្រម និងការកាត់ទោស ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១១ ("សាលក្រម រឿងក្តី *Bizimungu*") កថាខណ្ឌ ៧៤។ រឿងក្តី *Kanyabashi,* ICTR-96-15-I, សេចក្តីសម្រេចលើញត្តិបន្ទាន់បំផុតរបស់មេធាវីការពារក្តីស្តីពីដីកាឲ្យនាំខ្លួនមកតុលាការ និងការបញ្ឈប់កិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០០, កថាខណ្ឌ ៦៨ ("ភាពសមហេតុផលនៃថិរវេលាមិនអាចត្រូវបានបកស្រាយទៅជាចំនួនថ្ងៃ ឬឆ្នាំតាមកាលកំណត់បានទេ")។ រឿងក្តី *Nyiramasuhuko និងគូកន*, ICTR-98-42-A, សាលក្រម ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ("សាលក្រម រឿងក្តី *Nyiramasuhuko*") កថាខណ្ឌ ៣៥៩។ **ICC**: រឿងក្តី *Bemba*, ICC-01/05-01/08-3694, សេចក្តីសម្រេចលើការទាមទាររបស់លោក Bemba សុំទូទាត់សំណងចំពោះការខូចខាត, ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ កថាខណ្ឌ ៦៧ ("តាមក្របខណ្ឌតុលាការ [...] គ្មានពេលវេលាកំណត់ទេ ទាំងចំពោះដំណាក់កាលខុសៗគ្នានៃកិច្ចដំណើរការនីតិវិធី ហើយសំខាន់បំផុតនោះ គឺទាំងអំពីថិរវេលានៃការឃុំឃាំង មិនថាក្នុងដំណាក់កាលកិច្ចដំណើរការនីតិវិធីនីមួយៗ ឬទាំងមូលឡើយ")។

[22] *ផ្ទុយពី* ឯកសារ **D272** សំណើសុំបញ្ចប់, ទំព័រ ១, ៣០, កថាខណ្ឌ ៥១ក-ខ, ឃ។

[23] វិធានផ្ទៃក្នុងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (វិសោធនកម្មលើកទី៩) ដែលបានកែប្រែនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ("វិធាន" ឬ "វិធានផ្ទៃក្នុង"), វិធាន ២១(៤) ("ការសម្រេចសេចក្តីលើការចោទប្រកាន់ចំពោះមុខ អ.វ.ត.ក ត្រូវធ្វើការជំនុំជម្រះ*ក្នុងរយៈពេលមួយសមស្រប*" (សង្កត់ន័យដើម))។

[24] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ("កិច្ចព្រមព្រៀង អ.វ.ត.ក") មាត្រា ១២(២) ("អង្គជំនុំជម្រះវិសាមញ្ញ ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន សមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ១៩៦៦ ["ICCPR"] ដែលកម្ពុជាជាភាគីហត្ថលេខី")។ ICCPR មាត្រា ១៤(៣)(គ) ("ក្នុងការកំណត់អំពីបទចោទព្រហ្មទណ្ឌណាមួយប្រឆាំងជនណាម្នាក់ ជននោះមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ [...] (គ) ត្រូវបានជំនុំជម្រះ*ដោយឥតពន្យារពេលសមរម្យ*" (សង្កត់ន័យដើម))។ *សូមមើល ផងដែរ* ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ជាមួយច្បាប់វិសោធនកម្មដែលបានប្រកាសឱ្យប្រើ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ("ច្បាប់ អ.វ.ត.ក") មាត្រា ៣៥ថ្មី ដែលចែងខុសក្នុងភាសាអង់គ្លេសថា "to be tried without delay" ("ត្រូវបានទទួលការជំនុំជម្រះដោយគ្មានការអូសបន្លាយ") ប៉ុន្តែនិយាយត្រូវនៅក្នុងភាសាបារាំងថា "À être jugée sans retard *excessif*" (សង្កត់ន័យដើម)។

*មានការពន្យារពេលសមរម្យ*"[25]។ ចំណុចនេះគឺស្របនឹងយុត្តិសាស្ត្រព្រហ្មទណ្ឌអន្តរជាតិ[26] និងលិខិតុបករណ៍សិទ្ធិមនុស្សតំបន់[27]។ ការវាយតម្លៃអំពីភាពមិនសមរម្យគឺត្រូវធ្វើឡើងទៅតាម"កាលៈទេសៈ" ដូច មាស មុត យល់ស្រប[28] ដែលរួមមានបីកត្តា៖ (i) ភាពស្មុគស្មាញនៃកិច្ចដំណើរការនីតិវិធី, (ii) អំពើប្រព្រឹត្តរបស់ជនជាប់ចោទ និង (iii) អំពើប្រព្រឹត្តិរបស់អាជ្ញាធរដែលពាក់ព័ន្ធ។ ការកំណត់អំពីភាពស្មុគស្មាញ រួមមាន ការវាយតម្លៃពីចំនួនញត្តិស្នើសុំនិងសេចក្តីសម្រេចផ្ទាល់មាត់និងជាលាយលក្ខណ៍អក្សរ ខចោទ ទម្រង់នៃការទទួលខុសត្រូវ ជនជាប់ចោទនិងជនរងគ្រោះ ព្រមទាំងភាពស្មុគស្មាញនៃអង្គហេតុ និងអង្គច្បាប់ វិសាលភាពនៃពេលវេលានិងភូមិសាស្ត្រ និងបរិមាណនៃភ័ស្តុតាង[29]។

---

[25] សង្កត់ន័យដើម។

[26] *សូមមើល ឧទាហរណ៍* រឿងក្តី *Halilović*, IT-01-48-A, សេចក្តីសម្រេចលើញត្តិមេធាវីការពារក្តីសុំឱ្យធ្វើកាលវិភាគកំណត់ពេលសវនាការលើបណ្តឹងឧទ្ធរណ៍ឱ្យបានឆាប់ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៦, កថាខណ្ឌ ១៧ (ទទួលស្គាល់សិទ្ធិទទួលបានសវនាការឆាប់រហ័ស និងថា "សិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលសមរម្យ មិនបានធានាមិនឱ្យមានការពន្យារពេល*ណាមួយ* នៅក្នុងកិច្ចដំណើរការនីតិវិធី នោះទេ" (សង្កត់ន័យដើម))។ សាលក្រម រឿងក្តី *Nyiramasuhuko* AJ, កថាខណ្ឌ ៣៦៤។

[27] *សូមមើល ឧទាហរណ៍* (អឺរ៉ុប) អនុសញ្ញាស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ទីក្រុងរ៉ូម ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៥០, 213 UNTS 221 (ច្បាប់វិសោធនកម្ម) មាត្រា ៦(១) ("មានសិទ្ធិទទួលបានសវនាការដោយត្រឹមត្រូវយុត្តិធម៌ និងជាសាធារណៈនៅក្នុងរយៈពេលមួយសមស្រប")។ ធម្មនុញ្ញអាហ្វ្រិក (បានជុល) ស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជន ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១, CAB/LEG/67/3 វិសោធនកម្មលើកទី៥, 21 I.L.M. 58 (១៩៨២) មាត្រា ៧(១)(ឃ) ("សិទ្ធិទទួលបានការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប")។ អនុសញ្ញាស្តីពីសិទ្ធិមនុស្សអាមេរិកាំង ("កតិកាសញ្ញាសានចូសេ កូស្តារីកា", ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៦៩, ការរៀបចំរដ្ឋរបស់អាមេរិកាំង មាត្រា ៨(១) ("សិទ្ធិទទួលបានសវនាការ") [...] នៅក្នុងរយៈពេលមួយសមស្រប")។

[28] ឯកសារ **D272** សំណើសុំបញ្ចប់, កថាខណ្ឌ ៥០ *យោង* ឯកសារ **D120/3/1/8** សេចក្តីពិចារណាលើញត្តិសុំលុបចោលរបស់ចៅក្រមអន្តរជាតិ, កថាខណ្ឌ ៣៧។

[29] *សូមមើល ឧទាហរណ៍* <u>ICTR</u>: សាលដីការឿងក្តី *Nyiramasuhuko* កថាខណ្ឌ៣៦០, ៣៦២។ សាលក្រមរឿងក្តី *Bizimungu* កថាខណ្ឌ ៧៣, ៧៥។ រឿងក្តី *Renzaho*, ICTR-97-31-A, សាលដីកា ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៧ ("សាលដីការឿងក្តី *Renzaho*") កថាខណ្ឌ ២៣៨។ រឿងក្តី *Nahimana នឹងគូកន*, ICTR-99-52-A, សាលដីកា ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៧ ("សាលដីការឿងក្តី *Nahimana*")កថាខណ្ឌ១០៧៤។ រឿងក្តី *Rwamakuba*, ICTR-98-44C-PT, សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីសុំផ្អាកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០០៥ ("សេចក្តីសម្រេចផ្អាកកិច្ចដំណើរការនីតិវិធី រឿងក្តី *Rwamakuba*") កថាខណ្ឌ ២៩។ <u>ICTY</u>: សេចក្តីសម្រេចស្តីពីការបំពានដំណើរការក្នុងរឿងក្តី *Šešelj* កថាខណ្ឌ ៣០។ <u>STL</u>: រឿងក្តី *Ayyash នឹងគូកន*, STL-11-01/T/TC, សាលក្រម ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២០ ("សាលក្រម រឿងក្តី *Ayyash និងគូកន*") កថាខណ្ឌ ៩៦៦។

8. មាស មុត មើលរំលងភាពចាំបាច់នៃតុល្យភាពរវាងបុរេនិច្ឆ័យ ធៀបនឹងការពន្លឿនយុត្តិធម៌ នៅពេលកំណត់អំពី "ការពន្យារពេលមិនសមរម្យ"។ គាត់ធ្វើមិនដឹងមិនឮចំពោះសេចក្តីពិចារណាដ៏សំខាន់បំផុតចំនួនបីដែលពាក់ព័ន្ធជាពិសេសនឹងសំណុំរឿង ០០៣។ ទីមួយ អ.ប.ជ ត្រូវតែពិចារណាថា តើជនជាប់ចោទកំពុងតែ ឬបានជាប់ឃុំឬទេ[30]។ ទីពីរ ភាពធ្ងន់ធ្ងរនៃបទចោទ ក៏ត្រូវតែបានពិនិត្យមើលផងដែរ[31]។ ទីបី អាណត្តិរបស់ អ.វ.ត.ក -*ដើម្បីជំនុំជម្រះជនទាំងឡាយណាដែលស្ថិតក្រោមយុត្តាធិការរបស់ខ្លួន*[32]- មិនអាចធ្វើមិនដឹងមិនឮបានទេ ចំណែកសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល "ពាក់ព័ន្ធនឹងការថ្លឹងថ្លែងអំពីសិទ្ធិរបស់ជនជាប់ចោទជាមួយនឹងចុងបញ្ចប់នៃយុត្តិធម៌"[33] រួមទាំង តម្រូវការក្នុងការស្វែងរកការពិតអំពីឧក្រិដ្ឋកម្ម ដែលជនជាប់ចោទត្រូវបានចោទប្រកាន់ផង[34]។ ហេតុដូច្នេះ

---

[30] រឿងក្តី *Abdoella ទល់នឹង ប្រទេសហូឡង់* លេខ 12728/87, សាលក្រម ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩២ កថាខណ្ឌ ២៤ ("តុលាការសន្និដ្ឋានថា បើសិនបើជនណាម្នាក់បានជាប់ឃុំឃាំងរង់ចាំការសម្រេចអំពីបទចោទព្រហ្មទណ្ឌប្រឆាំងនឹងគាត់ នោះអង្គហេតុនៃការជាប់ឃុំឃាំងរបស់គាត់ គឺជាកត្តាមួយដែលនឹងត្រូវបានពិចារណានៅក្នុងការវាយតម្លៃអំពីថាតើ លក្ខខណ្ឌតម្រូវនៃសេចក្តីសម្រេចមួយលើអង្គសេចក្តីនៅក្នុងរយៈពេលមួយសមស្រប បានបំពេញដែរឬទេ")។ រឿងក្តី *Korshunov ទល់នឹង ប្រទេសរុស្ស៊ី* លេខ 38971/06, សាលក្រម ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៧ កថាខណ្ឌ ៧១ ("អង្គហេតុដែលថា គាត់បានជាប់ក្នុងមន្ទីរឃុំឃាំង តម្រូវឲ្យមានភាពហ្មត់ចត់ជាពិសេសទៅលើអាជ្ញាធរដែលពាក់ព័ន្ធនឹងករណី ក្នុងការគ្រប់គ្រងរដ្ឋបាលយុត្តិធម៌ឲ្យបានឆាប់រហ័ស")។ រឿងក្តី *Kryuk ប្រទេសរុស្ស៊ី* លេខ 11769/04, សាលក្រម ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ កថាខណ្ឌ ៦៧។ រឿងក្តី *Borisenko ទល់នឹង ប្រទេសអ៊ុយក្រែន* លេខ 25725/02, សាលក្រម ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១២ កថាខណ្ឌ ៥៨។ **UNHRC**: សេចក្តីអត្ថាធិប្បាយទូទៅ លេខ ៣២, មាត្រា ១៤: សិទ្ធិស្មើភាពគ្នាចំពោះមុខតុលាការ និងសាលាក្តី និងសិទ្ធិទទួលបានការជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌, CCPR/C/GC/32, ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ កថាខណ្ឌ ៣៥។

[31] *សូមមើល ឧទាហរណ៍ Šešelj* ការបំពានសេចក្តីសម្រេចស្តីពីដំណើរការ, កថាខណ្ឌ ២៩-៣០។ សេចក្តីសម្រេចផ្អាកក្នុងរឿងក្តី *Rwamakuba* កថាខណ្ឌ ១៩ ("ទម្ងន់នៃបទចោទ")។

[32] ច្បាប់ អ.វ.ត.ក មាត្រា ១, ២ថ្មី។ កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១។

[33] ឯកសារ **D120/3/1/8** សេចក្តីពិចារណាលើញត្តិសុំលុបចោលរបស់ចៅក្រមអន្តរជាតិ, កថាខណ្ឌ ៣៦។ *សូមមើល ផងដែរ Mugenzi និងគូកន*, ICTR-99-50-I, សេចក្តីសម្រេចលើញត្តិរបស់ Justin Mugenzi សុំផ្អាកកិច្ចដំណើរការនីតិវិធី ឬតាមជម្រើសផ្សេង សុំឲ្យដោះលែងជាបណ្តោះអាសន្ន (តាមវិធាន៦៥) និងនៅក្នុងការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម (តាមវិធាន ៨២(ខ)) ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០០២ កថាខណ្ឌ ៣២។ រឿងក្តី *Boddaert ទល់នឹង ប្រទេសបែលហ្ស៊ិក* លេខ 12919/87, សាលក្រម ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៩២ កថាខណ្ឌ ៣៩ ("មាត្រា ៦ [...] បញ្ជាឲ្យអនុវត្តកិច្ចដំណើរការនីតិវិធីតុលាការឲ្យបានឆាប់រហ័ស ប៉ុន្តែក៏បានដាក់ចេញនូវគោលការណ៍ដែលមានលក្ខណៈទូទៅខ្លាំងស្តីពីការគ្រប់គ្រងរដ្ឋបាលយុត្តិធម៌ឲ្យបានត្រឹមត្រូវផងដែរ") ដែលបានអនុវត្តនៅក្នុងសាលក្រមក្នុងរឿងក្តី *Coëme ទល់នឹង ប្រទេសបែលហ្ស៊ិក* កថាខណ្ឌ ១៤០។

[34] ឯកសារ **D120/3/1/8** សេចក្តីពិចារណាលើញត្តិសុំលុបចោលរបស់ចៅក្រមអន្តរជាតិ, កថាខណ្ឌ ៣៦។ រឿងក្តី *Neumeister ទល់នឹង ប្រទេសអូទ្រីស* លេខ 1936/63, សាលក្រម ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៦៨ កថាខណ្ឌ ២១។ ការបំពានសេចក្តី

អ.ប.ជ មានភារកិច្ច "ធ្វើការថ្លឹងថ្លែងអំពីសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលជាមួយនឹងភាពចាំបាច់ជាទូទៅសម្រាប់កិច្ចស៊ើបសួរ និងដំណើរការតុលាការដែលត្រូវពន្លឿន"[35]។

9. មាស មុត និយាយងាយៗទាំងមិនត្រូវអំពីភាពស្មុគស្មាញ និងភាពធ្ងន់ធ្ងរនៃសំណុំរឿង ០០៣ ដែលផ្ទុយពីអំណះអំណាងរបស់ខ្លួនឯងកាលពីមុន។ ដូចខាងលើ យើងបានឃើញច្បាស់ហើយថា មាស មុត មានកំហុសនៅក្នុងសេចក្តីថ្លែងដែលគ្មានមូលដ្ឋានរបស់គាត់ដែលថា "ភាពស្មុគស្មាញមិនអាចពន្យល់ ឬយកជាលេស" ចំពោះរយៈពេលនៃកិច្ចដំណើរការនីតិវិធីមុនការជំនុំជម្រះក្នុងសំណុំរឿង ០០៣ បាននោះ[36] គឺជាសេចក្តីថ្លែងផ្ទុយពីសេចក្តីថ្លែងមុនៗរបស់គាត់[37]។ លើសពីនេះ ការប្រៀបធៀបរបស់គាត់រវាង

---

សម្រេចស្តីពីដំណើរការក្នុងរឿងក្តី *Šešelj*, កថាខណ្ឌ ២៩។ រឿងក្តី *X ទល់នឹង សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់* លេខ 6946/75, សេចក្តីសម្រេច ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៧៦ ទំព័រ ១១៦ ("សហគមន៍អន្តរជាតិតម្រូវឱ្យអាជ្ញាធរមានសមត្ថកិច្ច [...]" ស៊ើបអង្កេត និងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្ម[សង្គ្រាម]ទាំងនេះ ទោះបីជួបការលំបាកផ្សេងៗដោយសារការកន្លងផុតទៅជាយូរនៃការប្រព្រឹត្តអំពើទាំងនោះក៏ដោយ [...]។ រយៈពេលនៃកិច្ចដំណើរការនីតិវិធីទាំងនេះ ត្រូវតែវាស់វែងស្របទៅតាមសេចក្តីពិចារណាខាងលើ[] ដោយមានការយកចិត្តទុកដាក់អំពីលក្ខណៈលើកលែង")។

[35] សំណុំរឿង ០០២-ឯកសារ **D314/1/8** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀងសារី និង នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១០, កថាខណ្ឌ ៧០។ ឯកសារ **D120/3/1/8** សេចក្តីពិចារណាលើញត្តិសុំលុបចោលរបស់ចៅក្រមអន្តរជាតិ, កថាខណ្ឌ ៣៦។

[36] ឯកសារ **D272** សំណើសុំបញ្ចប់, កថាខណ្ឌ ៥២។

[37] *សូមមើល ឧទាហរណ៍* ឯកសារ **D120/3/1/1** បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ដីកាសម្រេចចេញសាឡើងវិញរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើញត្តិរបស់ មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥, កថាខណ្ឌ ៤៩ ("សំណុំរឿង ០០៣ បែបមានភាពស្មុគស្មាញ ដោយហេតុថា រឿងក្តីនេះចាត់ការលើការចោទប្រកាន់អំពីឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដែលត្រូវបានចោទប្រកាន់ថា បានកើតឡើងតាំងពីប្រមាណសែសិបឆ្នាំមុនម្ល៉េះ")។ ឯកសារ **D249/2** សារណារបស់ មាស មុត ស្តីពីថវិកា, កថាខណ្ឌ ១ (ឧក្រិដ្ឋកម្មនៅក្នុងកម្ពុជាប្រជាធិបតេយ្យ "មានភាពស្មុគស្មាញ")។ ឯកសារ **D267/5/1** ទឡ្ហីករណ៍បន្ថែមរបស់ មាស មុត ទាក់ទងនឹងសំណើសុំពន្យារពេល និងបន្ថែមចំនួនទំព័រកំណត់សម្រាប់ចម្លើយ និង ការឆ្លើយតប ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៩, កថាខណ្ឌ ១ (អនុមតិតាមការកំណត់របស់ ស.ព.អ អំពីកិច្ចស៊ើបសួរនៃសំណុំរឿង ០០៣ ថា "មានភាពស្មុគស្មាញ")។ ឯកសារ **D266/13 & D267/18** សំណើរបស់ មាស មុត សុំអនុញ្ញាតមិនចូលបង្ហាញខ្លួនផ្ទាល់ក្នុងសវនាការលើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩, (សារណាស្តីពីសវនាការលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត) ទំព័រ ១, កថាខណ្ឌ ៤ (រៀបរាប់អំពី "ភាពស្មុគស្មាញនៃអំណះអំណាងផ្លូវច្បាប់ និងអង្គហេតុ" ដែលអាចនឹងកើតមាននៅក្នុងសវនាការលើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៣ របស់ អ.ប.ជ)។ ឯកសារ **D128.1/1/1** សំណើរបស់ មាស មុត សុំបន្ថែមចំនួនទំព័រនៃ បណ្តឹងឧទ្ធរណ៍លើការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេត Harmon អំពីបទចោទប្រកាន់ប្រឆាំង មាស មុត និងសុំដាក់ជាភាសាអង់គ្លេសសិន និងដាក់សំណៅបកប្រែជាភាសាខ្មែរជូនតាមក្រោយ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥, ទំព័រ ១, កថាខណ្ឌ ៧។ ឯកសារ **D128/1/1**

សំណុំរឿង ០០២ និង ០០៣[38] មិនអាចទទួលយកបាន និងជាការយល់ច្រឡំ។ សំណួរដែលត្រូវសួរគឺថាតើសំណុំរឿង០០៣ ស្មុគស្មាញដែរឬទេ មិនមែនថាតើសំណុំរឿង០០៣ ស្មុគស្មាញដោយសារប្រៀបធៀបទៅនឹងសំណុំរឿងផ្សេងនៅចំពោះមុខ អ.វ.ត.ក នោះទេ[39]។ ជាថ្មីម្ដងទៀត មាស មុត មិនបានបង្ហាញអង្គហេតុ និងប្រវត្តិនីតិវិធីនៃសំណុំរឿង០០៣ នៅកន្លែងណាមួយនៃការដាក់ឯកសារនេះឡើយ។

10. មាស មុត ថ្លែងមិនអស់សេចក្ដីអំពីភាពស្មុគស្មាញនៃអង្គហេតុនៃរឿងក្ដីនេះ។ ការយោងរបស់គាត់ទៅរកដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីរៀបរាប់សំណុំរឿង ០០៣ ថាជារឿងក្ដីមួយដែល "ពាក់ព័ន្ធជាមួយជនត្រូវចោទម្នាក់ ទាក់ទងនឹងទីតាំងនិងព្រឹត្តិការណ៍ឧក្រិដ្ឋកម្មចំនួនប្រាំបី និងតួនាទីរបស់កងទ័ពបដិវត្តន៍កម្ពុជា ("ក.ប.ក")[40] គឺគ្រាន់តែជាការបង្ហាញនូវចរិកលក្ខណៈយល់ច្រឡំដ៏ធំមួយទៀតអំពីការស៊ើបសួរនេះ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[41] និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម[42] បានប្ដឹងឲ្យ ស.ច.ស ស៊ើបអង្កេតទៅក្នុង ក.ប.ក *ទាំងមូល* ដើម្បីកំណត់អំពីការទទួលខុសត្រូវ[43] របស់ជនសង្ស័យពីរនាក់ (ពីដំបូង)[44] ក្នុងឋានៈជាមន្ត្រីយោធាជាន់ខ្ពស់[45] ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត

---

សំណើរបស់ មាស មុត សុំបន្ថែមចំនួនទំព័រនៃបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចដាក់ មាស មុត ឲ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥, ទំព័រ ១។

[38] ឯកសារ **D272** សំណើសុំបញ្ចប់, កថាខណ្ឌ ៥២។

[39] ដូចកត់សំគាល់ខាងលើ ការវាយតម្លៃអំពីភាពស្មុគស្មាញត្រូវធ្វើឡើងទៅតាមកាលៈទេសៈនៃករណីនីមួយៗ។ *សូមមើលបន្ថែម* ឯកសារ **D120/3/1/8** សេចក្ដីពិចារណាលើញត្តិសុំលុបចោលរបស់ចៅក្រមអន្តរជាតិ, កថាខណ្ឌ ៣៩-៤០។ សំណុំរឿង ០០២-ឯកសារ **C20/5/18** [កោសលុប] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរៈវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩, កថាខណ្ឌ ៥៧ និងសេចក្ដីយោងនៅក្នុងនោះ។ រឿងក្ដី *Davies ទល់នឹង ចក្រភពអង់គ្លេស* លេខ 42007/98, សាលក្រម ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០២, កថាខណ្ឌ ២៦។

[40] ឯកសារ **D272** សំណើសុំបញ្ចប់, កថាខណ្ឌ ៥២ *យោង* ឯកសារ **D267** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[41] ឯកសារ **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី២ របស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងកងទ័ពបដិវត្តកម្ពុជា ចុះថ្ងៃទី ២០-១១-២០០៨ ("IS")។

[42] ឯកសារ **D120** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្ដីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ ("SS")។

[43] អនុលោមតាមវិសាលភាពនៃទម្រង់នៃការទទួលខុសត្រូវ រួមទាំងសហឧក្រិដ្ឋកម្មរួម ("JCE")។ *សូមមើល* ឯកសារ **D1** IS, កថាខណ្ឌ ៩០-៩៨។ ឯកសារ **D120** SS, កថាខណ្ឌ ២៦។ *សូមមើល ផងដែរ* ឯកសារ **D267** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៥៦២-៥៧៧, EN 01596603-01596614, FR 01621343-01621352, KH 01600889-01600898។

[44] យ៉ាងហោចណាស់មកដល់ពាក់កណ្ដាលឆ្នាំ ២០១៣ ទើបមានជនសង្ស័យពីរនាក់នៅក្នុងសំណុំរឿង ០០៣ គឺ មាស មុត និង ស៊ូ ម៉េត។ នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣ ស.ច.ស បានជូនដំណឹងដល់ភាគីថា ស៊ូ ម៉េត បានស្លាប់ (ឯកសារ **D86** ការជូន

ដោយសមាជិកនានារបស់កងទ័ពជើងទឹក និងកងទ័ពអាកាសនៃកម្ពុជាប្រជាធិបតេយ្យ *នៅទូទាំង*កម្ពុជា រួមទាំងដែនទឹក និងដែនកោះរបស់ខ្លួននៅក្នុងយុត្តាធិការពេលវេលា *ទាំងមូល*របស់ អ.វ.ត.ក។ ដោយបានកំណត់អត្តសញ្ញាណទីតាំង និងព្រឹត្តិការណ៍ឧក្រិដ្ឋកម្មជាក់លាក់ជាច្រើន ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមបានប្ដឹងឲ្យ ស.ច.ស ស៊ើបអង្កេតទៅក្នុងការបោសសម្អាតផ្ទៃក្នុង ក.ប.ក ទាំងអស់ និងមន្ទីរសន្តិសុខ ហើយនឹងទីតាំងបោសសម្អាតពាក់ព័ន្ធ ក.ប.ក ទាំងអស់[46]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមបានស្នើបន្ថែមទៀតឲ្យស៊ើបអង្កេតទៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ[47]។ ការនេះបានធ្វើឡើងរហូតដល់ចុងបញ្ចប់នៃកិច្ចស៊ើបសួរទើបបានការស្រាវជ្រាវនេះលែងមាន ស្របតាមវិធាន ៦៦*ស្ទួន* ទាក់ទងនឹងចំនួនទីតាំង និងព្រឹត្តិការណ៍ឧក្រិដ្ឋកម្ម[48]។

---

ដំណឹងអំពីការស្លាប់របស់ជនសង្ស័យម្នាក់នៅក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣)។ កិច្ចដំណើរការនីតិវិធីប្រឆាំងជននេះ ត្រូវបានរំលត់នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៥។ (ឯកសារ **D86/3** ការលើកលែងការចោទប្រកាន់ប្រឆាំង ស៊ូ ម៉េត ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៥)។

[45] ទាំង មាស មុត និងទាំង ស៊ូ ម៉េត សុទ្ធតែធ្លាប់មានតួនាទី *ជាច្រើន* នៅក្នុងឋានានុក្រមកម្ពុជាប្រជាធិបតេយ្យ។ *សូមមើល* ឯកសារ **D1** IS, កថាខណ្ឌ ២, ៦៨-៧៤ (ស៊ូ ម៉េត), ៣, ៨១-៨៦ (មាស មុត)។ ឯកសារ **D120** SS, កថាខណ្ឌ ១២-១៤ (មាស មុត)។ ឯកសារ **D267** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៤៩-១៧០, ៤៥៩, ៤៦១។

[46] ឯកសារ **D1** IS, កថាខណ្ឌ ៤៣-៥៨, ៦៣-៦៦។ ឯកសារ **D120** SS, កថាខណ្ឌ ៦-១៤, ១៨-១៩។ អង្គហេតុទាក់ទងនឹងប្រតិបត្តិការរបស់ ក.ប.ក ទាំងមូល រួមទាំងការបោសសម្អាតផង ក៏ជាចំណុចសំខាន់បំផុតក្នុងកំណត់អំពីអត្ថិភាពនៃ JCE ផងដែរ។ *សូមមើល* ឯកសារ **D1** IS, កថាខណ្ឌ ៣៣-៤១, ៦៥-៦៦។ *សូមមើលបន្ថែម* ឯកសារ **D120/3** ដីកាសម្រេចសាឡើងវិញលើញត្តិរបស់ មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០១៥, កថាខណ្ឌ ៣២។ ឯកសារ **D120/3/1/8** សេចក្តីពិចារណាលើញត្តិសុំលុបចោលរបស់ចៅក្រមអន្តរជាតិ, កថាខណ្ឌ ៤២។

[47] ឯកសារ **D120** SS, កថាខណ្ឌ ២០-២៤។

[48] *សូមមើល* **D184** សំណើសុំមតិយោបល់ទាក់ទងនឹងការចោទប្រកាន់អំពីអង្គហេតុដែលនឹងមិនស៊ើបអង្កេតថែមទៀតទេ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ ("អង្គហេតុដែលមិនស្នើឲ្យស៊ើបសួរ")។ ឯកសារ **D184/3** សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦។ ឯកសារ **D184/4** សេចក្តីជូនដំណឹងយោងតាមវិធានផ្ទៃក្នុង ៦៦ស្ទួន(២) ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៦។ ឯកសារ **D226** ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរយោងតាមវិធានផ្ទៃក្នុង ៦៦ស្ទួន ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧។ អង្គហេតុទាំងនេះគឺ (i) ការចោទប្រកាន់ទាំងអស់ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខស-២២; (ii) ការចោទប្រកាន់ទាំងអស់ពាក់ព័ន្ធនឹងការដ្ឋានកសាងព្រលានយន្តហោះកំពង់ឆ្នាំង; (iii) ការចោទប្រកាន់ទាំងអស់ពាក់ព័ន្ធនឹងទីតាំងសម្លាប់មនុស្សស្ទឹងតូច និង (iv) ការចោទប្រកាន់ទាំងអស់ពាក់ព័ន្ធនឹងការពាក់ព័ន្ធរបស់ ក.ប.ក នៅក្នុង "ការបោសសម្អាត" ភូមិភាគកណ្ដាល ភូមិភាគឧត្តរថ្មី និងភូមិភាគបូព៌ា ដោយមិនរាប់បញ្ចូល "ការបោសសម្អាត" ដែលបានចោទប្រកាន់លើសមាជិកនៃអង្គភាព ក.ប.ក ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ទាំងនោះទេ។ អង្គហេតុផ្សេងទៀតត្រូវលើកលែងអនុលោមតាមវិធាន ៦៧ រួមមាន ការចោទប្រកាន់ទាក់ទងនឹង (i) ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងប្រទេសវៀតណាម; (ii)

11. មាស មុត ក៏មើលរំលងភាពស្មុគស្មាញផ្លូវច្បាប់នៃសំណុំរឿង ០០៣ ផងដែរ។ ការចោទប្រកាន់ផ្នែកអង្គហេតុយ៉ាងធំដូចបានរៀបរាប់ខាងលើ បានឆ្លុះបញ្ចាំងតាមរយៈការកំណត់ចរិកលក្ខណៈផ្លូវច្បាប់ជាច្រើនចាប់ពីឧក្រិដ្ឋកម្មថ្នាក់ប្រទេស រហូតដល់អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើប្រល័យពូជសាសន៍[49]។ លើសពីនេះ ដូចមានភ័ស្តុតាងបង្ហាញស្រាប់នៅក្នុងប្រវត្តិនីតិវិធីដែលបានដាក់ទៅក្នុងសំណុំរឿង ០០៣[50] រឿងក្តីនេះបានតម្រូវឱ្យមានការមិនយល់ស្របតាមវិធានផ្ទៃក្នុង[51] បញ្ហាច្បាប់ថ្មីៗ[52] និងលក្ខខណ្ឌតម្រូវ *ជាអាទិ៍* ការត្រួតពិនិត្យលើសំណុំរឿង០០១ និង ០០២ ដើម្បីរកភ័ស្តុតាងពាក់ព័ន្ធ និងដោះស្រាយញត្តិស្នើសុំ សំណើសុំបំពេញកិច្ច

---

គុក ៨១០; (iii) ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងមន្ទីរសន្តិសុខដែលបានស្គាល់អត្តសញ្ញាណផ្សេងទៀត ដែលបានធ្វើប្រតិបត្តិការដោយ ក.ប.ក។ *សូមមើលបន្ថែម* ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ("ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ"), កថាខណ្ឌ ៣៤-៣៦។

[49] ឯកសារ **D1** IS, កថាខណ្ឌ ៩៩។ ឯកសារ **D120** SS, កថាខណ្ឌ ២៥។ ឯកសារ **D174** កំណត់ហេតុនៃការស្តាប់ចម្លើយនៃការបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ("កំណត់ហេតុនៃការស្តាប់ចម្លើយនៃការបង្ហាញខ្លួនលើកដំបូង"), ទំព័រ ២-៣ (បញ្ចូលបទចោទនៃអំពើប្រល័យពូជសាសន៍)។ *សូមមើលផងដែរ* ឯកសារ **D267** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤៧០-៥៦១, EN 01596603-01596614, FR 01621343-01621352, KH 01600889-01600898។

[50] *សូមមើល ឧទាហរណ៍* ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៦-៤៧។ ឯកសារ **D267** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌ ១-២៧។ ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ("ដីកាសម្រេចលើកលែងចោទប្រកាន់"), កថាខណ្ឌ ១៥-៣៥។ ឯកសារ **D266/27** & **D267/35** សេចក្តីពិចារណា, កថាខណ្ឌ ១-៣៦។

[51] វិធាន ៧១-៧២ នៃវិធានផ្ទៃក្នុង។

[52] *សូមមើល ឧទាហរណ៍* ឯកសារ **D191/18** ការជូនដំណឹងស្តីពីការបកស្រាយ "ការវាយប្រហារទៅលើប្រជាជនស៊ីវិល" នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់របប ឬរដ្ឋនោះ ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៧។ ឯកសារ **D184** អង្គហេតុដែលមិនស្នើឱ្យស៊ើបសួរ។ *សូមមើល ផងដែរ* ឯកសារ **D214** ញត្តិរបស់ មាស មុត ជំទាស់ការអនុវត្តអាពាហ៍ពិពាហ៍ដោយបង្ខំជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងទម្រង់ជាអំពើអមនុស្សធម៌ផ្សេងទៀត ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៦។ ឯកសារ **D145** ញត្តិរបស់ មាស មុត ប្រឆាំងនឹងការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើ ចំពោះឧក្រិដ្ឋកម្មដែលមិនពាក់ព័ន្ធទៅនឹងជម្លោះប្រដាប់អាវុធអន្តរជាតិ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៥។ ឯកសារ **D87/2/1.7** សំណើរបស់លោក មាស មុត សុំការបំភ្លឺបញ្ជាក់ថាតើ ក.ស.ច.ស ពិចារណាថាការិយាល័យនេះជាប់កាតព្វកិច្ចទៅនឹងយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ ឬយ៉ាងណា ដែលថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតម្រូវឱ្យមានចំណងទាក់ទងជម្លោះប្រដាប់អាវុធ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៣។

ស៊ើបសួរ ពាក្យសុំមោឃភាពនិងបណ្តឹងឧទ្ធរណ៍មួយចំនួន[53]។ ពេលបិទកិច្ចស៊ើបសួរ សំណុំរឿង០០៣ មានឯកសារ ៧,០០០ ដែលរួមមានទាំងកំណត់ហេតុសួរ/ស្តាប់ចម្លើយចំនួន ៩០០ ផង[54]។ លើសពីនេះ គិតត្រឹមពេលចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ មានជនរងគ្រោះចំនួន ៦៤៦ នាក់ បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០៣[55]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[56] ដីកាសន្និដ្ឋានស្ថាពរ[57] និងចម្លើយតបរបស់ មាស មុត ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ[58] ព្រមទាំងដីកាដំណោះស្រាយទាំងពីរ[59] និងសេចក្តីសម្រេចលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[60] ដែលនីមួយៗមានចំនួនរាប់រយទំព័រសឹងតែគ្មានការលើកលែង[61]។ នៅដំណាក់កាលមុនការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ បណ្តឹងឧទ្ធរណ៍

---

[53] *សូមមើល ឧទាហរណ៍* ឯកសារ **D267.2** ឧបសម្ព័ន្ធ II: សារណា និងសំណើសុំដែលបានដាក់ជូន ស.ច.ស ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ (វាយឈ្មោះការដាក់ឯកសារនិងសំណើចំនួន ១៧៥ ដែលបានដាក់ជូន ស.ច.ស មុនចេញដីកាដំណោះស្រាយ។ ក្នុងចំនួននេះ មាន ១៦២ បានដាក់ក្រោយថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ ចំនួន ១១៨ បានដាក់ដោយ មាស មុត។ មានចំនួន ៤២ ក៏ពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.ប.ជ ផងដែរ)។ ជាការបន្ថែម ក.ស.ច.ស និង អ.ប.ជ បានបំពេញកិច្ចតាមផ្លូវតុលាការចាំបាច់ផ្សេងៗទៀតក្នុងទម្រង់ជាសេចក្តីសម្រេច ដីកាសម្រេច ញត្តិ អនុស្សរណៈ សំណើ ចម្លើយតប និងការឆ្លើយតប។ ជារួម ការស្រាវជ្រាវមួយក្នុង Zylab ដើម្បីរកឯកសារនានាជាភាសាអង់គ្លេស បានបង្ហាញឱ្យឃើញនូវចំនួនប៉ាន់ស្មានដ៏ប្រយ័ត្នប្រយែងមួយគឺ ២៤៥ ឯកសារ ពី ក.ស.ច.ស និងចំនួន ៧៩ ពី អ.ប.ជ ចាប់តាំងពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២។

[54] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៤១។

[55] ឯកសារ **D269** ដីកាសម្រេចលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ("ដីកាសម្រេចលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ស.ច.ស.អ"), កថាខណ្ឌ ២។

[56] **ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (D1)**: **អង់គ្លេស:** ១១៨ ទំព័រ, **ខ្មែរ:** ១៣៣ ទំព័រ, **បារាំង:** ១៣៨ ទំព័រ។ **ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម (D120)**: **អង់គ្លេស:** ១៧ ទំព័រ, **ខ្មែរ:** ២៦ ទំព័រ, **បារាំង:** អត់ដឹង។

[57] **ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ (D256/7)**: **អង់គ្លេស:** ៩៤៤ ទំព័រ (បូកនឹង ឧបសម្ព័ន្ធចំនួន ១៤), **ខ្មែរ:** ១៦០៥ ទំព័រ (បូកនឹង ឧបសម្ព័ន្ធចំនួន ១៤), **បារាំង:** អត់ដឹង។ **ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.ជ (D256/6)**: **អង់គ្លេស:** ១១ ទំព័រ, **ខ្មែរ:** ១៦ ទំព័រ, **បារាំង:** អត់ដឹង។

[58] **ចម្លើយតបរបស់ មាស មុត (D256/11)**: **អង់គ្លេស:** ៣១៨ ទំព័រ, **ខ្មែរ:** ៤៩៦ ទំព័រ, **បារាំង:** អត់ដឹង។

[59] **ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267)**: **អង់គ្លេស:** ២៦៥ ទំព័រ, **ខ្មែរ:** ៤៣១ ទំព័រ, **បារាំង:** ៣១៣ ទំព័រ។ **ដីកាសម្រេចលើកលែងចោទប្រកាន់ (D266)**: **អង់គ្លេស:** ២១៥ ទំព័រ, **ខ្មែរ:** ៣៥៥ ទំព័រ, **បារាំង:** ១៧៩ ទំព័រ។

[60] **ដីកាសម្រេចលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ស.ច.ស.អ (D269)**: **អង់គ្លេស:** ១១ ទំព័រ (បូកនឹង ឧបសម្ព័ន្ធចំនួន ៥), **ខ្មែរ:** ២០ ទំព័រ (បូកនឹង ឧបសម្ព័ន្ធចំនួន ៥), **បារាំង:** ១២ ទំព័រ (បូកនឹង ឧបសម្ព័ន្ធចំនួន ៥)។ **ដីកាសម្រេចលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ស.ច.ស.ជ (D268)**: **អង់គ្លេស:** ៣ ទំព័រ, **ខ្មែរ:** ៤ ទំព័រ, **បារាំង:** អត់ដឹង។

[61] ចំនួនទំព័រគិតតាមការបង្ហាញនៅលើ Zylab រួមទាំងទំព័រមុខ និងតារាងមាតិកាទាំងអស់។

របស់ភាគី[62] ហើយនឹងសេចក្តីពិចារណាពីរឈុតរបស់ អ.ប.ជ គឺសុទ្ធតែមានចំនួនច្រើន[63]។

12. មាស មុត ខកខានមិនបានទទួលស្គាល់ការចូលរួមចំណែករបស់គាត់ក្នុងការពន្យារពេលទាំងនេះ។ គាត់បានអះអាងទាំងខុសថា មិនបាននាំឲ្យមានការពន្យារពេលណាមួយឡើយ[64]។ ខណៈដែល ស.ច.ស.អ Bohlander ដែលបានចោទប្រកាន់គាត់ដោយផ្ទាល់នៅក្នុងខេត្តបាត់ដំបង ក្នុងខែធ្នូ ឆ្នាំ២០១៥ ប្រហែលជាមិនបានពន្យារពេលកិច្ចដំណើរការនីតិវិធី *នេះដោយផ្ទាល់ទេនោះ* ការណ៍នេះមើលរំលងចំណុចដែលថា យូរណាស់មកហើយដែល មាស មុត ខកខានមិនបានបង្ហាញខ្លួននៅចំពោះមុខ អ.វ.ត.ក។ ក្នុងឆ្នាំ ២០១៤ នៅពេលដែលត្រូវបានកោះហៅដោយ ស.ច.ស.អ Harmon ឲ្យបង្ហាញខ្លួនលើកដំបូង[65] គាត់បានបដិសេធមិនព្រមមកបង្ហាញខ្លួន[66] ដែលបានតម្រូវឲ្យ ស.ច.ស.អ ចាត់វិធានការបែបនីតិវិធីបន្ថែមទៀត ដោយរួមទាំងការចេញដីកាបង្គាប់ឲ្យនាំខ្លួនជាច្រើន[67] ដែល មាស មុត បានជំទាស់[68]។

---

[62] <u>បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ (D266/2)</u>: **អង់គ្លេស:** ១០៤ ទំព័រ, **ខ្មែរ:** ១៧៥ ទំព័រ, **បារាំង:** ១២៦ ទំព័រ។ <u>**បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ (D267/3)**</u>: **អង់គ្លេស:** ៣៧ ទំព័រ, **ខ្មែរ:** ៥៣ ទំព័រ, **បារាំង:** ៨៤ ទំព័រ។ <u>**បណ្តឹងឧទ្ធរណ៍របស់ មាស មុត (D267/4)**</u>: **អង់គ្លេស:** ៤៩ ទំព័រ, **ខ្មែរ:** ៧៨ ទំព័រ, **បារាំង:** ៦១ ទំព័រ។ <u>**បណ្តឹងឧទ្ធរណ៍របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី (D269/3)**</u>: **អង់គ្លេស:** ៤១ ទំព័រ, **ខ្មែរ:** ៥៧ ទំព័រ, **បារាំង:** អត់ដឹង។

[63] <u>**សេចក្តីពិចារណា (D266/27 & D267/35)**</u>: **អង់គ្លេស:** ១៥២ ទំព័រ, **ខ្មែរ:** ២១៦ ទំព័រ, **បារាំង:** ១៧៥ ទំព័រ។ <u>**សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី (D269/4)**</u>: **អង់គ្លេស:** ៤៩ ទំព័រ, **ខ្មែរ:** ៧០ ទំព័រ, **បារាំង:** ៥៦ ទំព័រ។

[64] **D272** សំណើ សុំបញ្ចប់ កថាខណ្ឌ ៥៣។

[65] ឯកសារ **A66** ដីកាកោះលោក មាស មុត ដើម្បីបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤។ ឯកសារ **A66/1** កំណត់ហេតុនៃការប្រគល់ដីកាកោះ ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៤។ ឯកសារ **A67** ដីកាកោះមេធាវី ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤។ ឯកសារ **D82/5** ការជូនដំណឹងស្តីពីសំណើរបស់ជនសង្ស័យសុំចូលពិនិត្យមើលសំណុំរឿងចូលរួមការស៊ើបអង្កេត និងសុំលុបចោលចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤។

[66] ឯកសារ **A67/1** សេចក្តីជូនដំណឹងទាក់ទងនឹងសេចក្តីសម្រេចចិត្តរបស់លោក មាស មុត មិនទទួលស្គាល់ដីកាកោះ ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៤។ ឯកសារ **A67/1.1** សេចក្តីជូនដំណឹងស្តីពីការមិនទទួលស្គាល់ដីកាកោះ ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៤។ ឯកសារ **A77** ពាក្យប្តឹងរបស មាស មុត សុំប្តឹងអង្គបុរេជំនុំជម្រះឲ្យទទួលពិនិត្យ និង ចាត់ការលើសំណើសុំមោឃភាពដីកាកោះឲ្យបង្ហាញខ្លួនបឋម ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៤។

[67] ឯកសារ **C1** ដីកាបង្គាប់ឲ្យនាំខ្លួន ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៤។ ឯកសារ **C2** ដីកាបង្គាប់ឲ្យនាំខ្លួន ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៥។

[68] ឯកសារ **D130** សំណើរបស់ មាស មុត សុំឲ្យទុកជាមោឃៈនូវដីកាបង្គាប់ឲ្យនាំខ្លួនដែលបានចេញនៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ២០១៤ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥។ ឯកសារ **C2/1** សំណើបន្ទាន់របស់ មាស មុត សុំផ្អាកការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួនដែលចេញនៅ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ ដោយសហចៅក្រមស៊ើបអង្កេត HARMON ដើម្បីរង់ចាំសេចក្តីសម្រេចលើ

ស.ច.ស.អ បានបង្ខំចិត្តដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ*[69] ជាថ្មីម្តងទៀត វាគឺជាសេចក្តីសម្រេចដែលគាត់បានជំទាស់ ទោះបីជាវាត្រូវបានកើតឡើងដោយការខកខានមិនបានបង្ហាញខ្លួនរបស់គាត់យ៉ាងណាក្តី[70]។ ខណៈដែល មាស មុត អាចជំទាស់ទៅនឹងសេចក្តីសម្រេចនានា នៅពេលដែលបញ្ហាទាំងនេះត្រូវបានសម្រេចដោយ អ.ប.ជ ហើយនោះ ការខកខានមិនគោរពតាមសេចក្តីសម្រេចដែលបានចេញយ៉ាងមានសុពលភាព[71] ចូលរួមចំណែកក្នុងកិច្ចដំណើរការនីតិវិធីដែលអូសបន្លាយពេលយូរនេះ។

13. មាស មុត ខកខានមិនបានបង្ហាញពីផលប៉ះពាល់ពិតប្រាកដណាមួយនៃកិច្ចដំណើរការនីតិវិធីលើជីវិតប្រចាំថ្ងៃរបស់ឡើយ។ គាត់មិនបានគាំទ្រការអះអាងរបស់គាត់ដែលថា គាត់បានរស់នៅដោយទទួលរងសម្ពាធ និងការម៉ាក់ងាយជាសាធារណៈ ក្នុងរយៈពេល ១៣ឆ្នាំកន្លងមកនេះ[72] ហើយគាត់ក៏មិនបានផ្តល់មូលដ្ឋានណាមួយដើម្បីសន្និដ្ឋានថា ជីវិតរស់នៅប្រចាំថ្ងៃរបស់គាត់ក្នុងប្រទេសកម្ពុជាទទួលរងការប៉ះពាល់នោះទេ។ មាស មុត បានរស់នៅយ៉ាងសេរីក្នុងរយៈពេលនៃការស៊ើបអង្កេតទាំងមូល។ គាត់មិនដែលបានស្ថិតក្នុងការឃុំខ្លួននៅ អ.វ.ត.ក ឡើយ[73] ហើយក៏មិនស្ថិតក្នុងការរឹតត្បិតដ៏មានអត្ថន័យណាមួយលើសេរីភាពផ្ទាល់ខ្លួនរបស់គាត់ឡើយ គាត់គ្រាន់តែចាំបាច់ត្រូវ "បង្ហាញខ្លួនតាមតម្រូវការរបស់ អ.វ.ត.ក" ដោយស្ទើរតែមិនមានលក្ខខណ្ឌណាជាប់ជាមួយទេ[74]។ សេរីភាពក្នុងការផ្លាស់ទី និង

---

បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត HARMON ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតនៅក្រោមការពិនិត្យ *ដោយកំបាំងមុខ* ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៥។

[69] ឯកសារ **D128** ដីកាសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥។

[70] ឯកសារ **D128/1/3** បណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រមការពិនិត្យ *ដោយកំបាំងមុខ* ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥។

[71] ឯកសារ **D117/1/1/2** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសំណើរបស់ជនសង្ស័យទាក់ទងនឹងដីកាកោះ ដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៤ កថាខណ្ឌ ៩។

[72] ឯកសារ **D272** សំណើ សុំបញ្ចប់ កថាខណ្ឌ ៥៤។

[73] **D174** កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ទំព័រ ១១។ ឯកសារ **D267** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៥៧៨-៥៧៩។

[74] **D174** កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ទំព័រ ១១ (តាមវិធីអនុវត្ត មាស មុត ត្រូវជូនដំណឹងដល់ ស.ច.ស.អ អំពីការផ្លាស់ប្តូរអាសយដ្ឋានណាមួយ។ គាត់យល់ព្រមទទួលយកការពិនិត្យប្រចាំសប្តាហ៍នៅលំនៅដ្ឋានរបស់គាត់ដោយប៉ូលីស។ គាត់ក៏ព្រមជូនដំណឹង ស.ច.ស.អ - ដោយខ្លួនគាត់ផ្ទាល់ ឬតាមរយៈមេធាវីរបស់គាត់ - នៅពេលណាដែលគាត់ចង់ចាកចេញពីប្រទេសទៅព្យាបាលជំងឺ និងនៅពេលត្រឡប់មកវិញ)។ *សូមមើលផងដែរ* ឯកសារ **D174/2** ដីកាស្តីពីការអនុវត្តតាម

ការបង្កើតសមាគម របស់គាត់មិនត្រូវបានបះពាល់ទេ។ ក្នុងឆ្នាំ២០១៦ គាត់ទទួលបានលិខិតឆ្លងដែនថ្មី ដែលគាត់ខកខានមិនបានប្រកាស ឬប្រគល់[75] ទោះបីជាមានការធានាដែលគាត់បានផ្តល់ឲ្យ អ.វ.ត.ក ក៏ដោយ[76] ហើយគាត់បានធ្វើដំណើរជាប្រចាំទៅប្រទេសថៃ ដើម្បីព្យាបាលជំងឺអស់រយៈពេលជាច្រើនឆ្នាំ[77]។ ក្នុងឆ្នាំ ២០១៩ គាត់បានចូលរួមពិធីបុណ្យសពរបស់ នួន ជា ជាមួយនឹងអតីតមេដឹកនាំកម្ពុជាប្រជាធិបតេយ្យផ្សេងទៀត[78]។

14. មាស មុត ទាយស្មានមិនត្រឹមត្រូវចំពោះអនាគតនៃកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ប្រឆាំងនឹង

---

ការធានាអះអាងដែល មាស មុត បានធ្វើឡើងដោយស្ម័គ្រចិត្តនៅពេលបង្ហាញខ្លួនលើកដំបូងចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៦ កថាខណ្ឌ ១ (ដែលតម្រូវឲ្យ មាស មុត (i) ប្រគល់លិខិតឆ្លងដែនដែលមានសុពលភាពជូនទៅប៉ូលីសមិនឲ្យហួសរយៈពេលប្រាំពីរថ្ងៃ (ii) មានវត្តមាននៅលំនៅដ្ឋាននៅពេលនគរបាលចុះទៅពិនិត្យរៀងរាល់សប្តាហ៍ និង (iii) ជូនដំណឹងទៅប៉ូលីសប្រសិនបើគាត់សម្រេចចិត្តផ្លាស់ប្តូរទីលំនៅ) ២ (បានជូនដំណឹង មាស មុត ថា គាត់អាចទទួលបានលិខិតឆ្លងដែនរបស់គាត់ជាបណ្តោះអាសន្ន ដើម្បីចាកចេញពីប្រទេសកម្ពុជាទៅព្យាបាលជំងឺ ឬដោយមូលហេតុបន្ទាន់ផ្សេងទៀត *ក្នុងលក្ខខណ្ឌ* ដែលថាគាត់ផ្តល់ភ័ស្តុតាងបញ្ជាក់ពីការណាត់ជួបព្យាបាលនៅក្រៅប្រទេស ឬមូលហេតុបន្ទាន់ផ្សេងទៀត និង បញ្ជាក់ពីរយៈពេលដែលគាត់គ្រោងនៅក្រៅប្រទេស។ ករណីនេះត្រូវអនុវត្តដូចគ្នាប្រសិនបើ មាស មុត ត្រូវចាកចេញពីប្រទេស កម្ពុជាដោយមិនតម្រូវឲ្យមានលិខិតឆ្លងដែនសម្រាប់ការធ្វើដំណើរក៏ដោយ។ មាស មុត ត្រូវជូនដំណឹងដល់ប៉ូលីសនៅពេលគាត់ ត្រឡប់មកវិញដោយប្រគល់លិខិតឆ្លងដែនរបស់គាត់ឲ្យប៉ូលីសវិញ) ៣ (ត្រូវរៀបចំរបាយការណ៍ឆ្លើយឆ្លងទៅកាន់នគរបាល យុត្តិធម៌)។

[75] ឯកសារ **D266/18.2 & D267/23.2** ប្រតិចារឹកសវនាការ អ.ប.ជ ក្នុងរឿងក្តី ០០៣ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ម៉ោង 12.08.05-12.13.22 (មេធាវីការពារក្តីអន្តរជាតិរបស់ មាស មុត លោក Michael Karnavas បានបញ្ជាក់ថា (i) គាត់បានដឹងក្នុងរយៈពេល២៤ម៉ោង មុនថា មាស មុត បានទទួលលិខិតឆ្លងដែនមានសុពលភាពក្នុងឆ្នាំ២០១៦ដែលមិនបានប្រគល់ឲ្យ ប៉ូលីស និង (ii) ទាំងនៅមុន និងក្រោយមក មាស មុន ត្រូវបានចោទប្រកាន់ផ្លូវការដោយ ស.ច.ស.អ "វាមិនមែនមិនធម្មតា" នោះទេសម្រាប់គាត់ក្នុងការឆ្លងព្រំដែនដោយគ្មានលិខិតឆ្លងដែនដើម្បីព្យាបាលជំងឺក្នុងប្រទេសថៃ រួមទាំងការវះកាត់បះដូងចំហរផង)។

[76] *សូមមើលយោងខាងលើ* ជើងទំព័រ ៧៤។

[77] *សូមមើលយោងខាងលើ* ជើងទំព័រ ៧៥។ *សូមមើលផងដែរ* ឯកសារ **D266/13 & D267/18** សារណាសវនាការបណ្តឹងឧទ្ធរណ៍របស់ មាស មុត កថាខណ្ឌ ២។

[78] *សូមមើលឧទាហរណ៍* Business Standard (AFP), *អ្នកកាន់ទុក្ខសំដែងការគោរពចុងក្រោយចំពោះ មេដឹកនាំខ្មែរក្រហមទីពីរ (Mourners pay final respects to Khmer Rouge 'Brother Number Two')*, ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៩ ("អតីតមេទ័ពជើងទឹកខ្មែរក្រហម មាស មុត ដែលត្រូវបានចោទប្រកាន់ពីបទប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផងដែរ នៅក្នុងរឿងក្តីជាប់គាំងមួយ ក៏បានចូលរួមក្នុងពិធីបុណ្យរយៈពេលយូរមួយនៅថ្ងៃសុក្រ ដោយបាននិយាយថាគាត់មក "លាដំណើរចុងក្រោយ"អតីតមេរបស់គាត់។")។ វីអូអេខ្មែរ *រឿងក្តីមេខ្មែរក្រហម ឆ្ពោះទៅកាន់តុលាការ នៅថ្ងៃទី២៧ ខែវិច្ឆិកា (Bellwether Khmer Rouge Case Heads to Court on November 27)* ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៩ (មានរូប មាស មុត នៅខាងមុខពិធីបុណ្យសព នួន ជា នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៩ និងឯកសារធ្វើដំណើររបស់គាត់ទៅប្រទេសថៃដើម្បីព្យាបាល ជំងឺ)។

គាត់។ ការទាយស្មានរបស់គាត់ទាក់ទងនឹងរយៈពេលយូរ ដែលអាចមាននៅពេលអនាគតនៃការជំនុំជម្រះ និងកិច្ចដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍ ឬលទ្ធផលជាទីគាប់ចិត្តណាមួយនៃបញ្ហាវិវាទ នៅក្នុងកិច្ចដំណើរការនីតិវិធីទាំងនោះ មិនអាចបង្កើតបានជាមូលដ្ឋានសម្រាប់បញ្ជាក់ពីការរំលោភលើកិច្ចដំណើរការនីតិវិធីដ៏ឆាប់រហ័សបានឡើយ[79]។ គេមិនអាចនិយាយថា សិទ្ធិមួយត្រូវបានរំលោភ*មុន*ពេលសិទ្ធិនោះត្រូវបានរំលោភឡើយ។ ចៅក្រម "មានអំណាចតែសម្រាប់កំណត់ថាតើ មានការរំលោភណាមួយលើសិទ្ធិរបស់ជនជាប់ចោទឬយ៉ាងណា តែត្រឹមកាលបរិច្ឆេទបច្ចុប្បន្ន"[80]។ ទោះជាយ៉ាងណាកិច្ចដំណើរការនីតិវិធីផ្អែកលើសេចក្តីសម្រេចរបស់តុលាការ និងមានប្រសិទ្ធភាពដូចសេចក្តីសម្រេចទាំងនោះកំណត់។ លទ្ធផលត្រូវផ្អែកលើច្បាប់ដែលអនុវត្តមិនលម្អៀង និងឯករាជ្យទៅលើអង្គហេតុដំណើរការបែបនេះនឹងមិនធានាឲ្យមានលទ្ធផលជាទីគាប់ចិត្តចំពោះ មាស មុត នោះឡើយ[81]។

15. មាស មុត យល់ច្រឡំចំពោះច្បាប់ដែលបានបង្កើតឡើង ស្តីពីយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក។ ក្នុងលក្ខខណ្ឌដែលថាការសន្និដ្ឋានរបស់គាត់ផ្អែកលើការអះអាង ដែលទាក់ទងនឹងការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ("អ.ជ.ស.ដ") នៅពេលអនាគតលើយុត្តាធិការបុគ្គល[82] ការសន្និដ្ឋានទាំង

---

[79] **D272** សំណើ សុំបញ្ចប់ ផ្នែក III.គ. (មានចំណងជើងថា "ដំណើរការនីតិវិធីជំនុំជម្រះ និងបណ្តឹងឧទ្ធរណ៍ក្នុងរឿងក្តី ០០៣ នឹងស៊ីពេលយ៉ាងតិចបួនឆ្នាំ ជាមួយនឹងលទ្ធផលដែលមិនអាចចៀសរួច") កថាខណ្ឌ ៥៦-៥៩, ៦២, ៦៧។

[80] *Bizimungu និងគូកន.*, ICTR-99-50-T, សេចក្តីសម្រេចលើញត្តិទីពីររបស់ Prosper Mugiraneza សុំឲ្យលើកលែងចោទប្រកាន់ដោយសារការបដិសេធសិទ្ធិរបស់គាត់ក្នុងការជំនុំជម្រះដោយមិនមានការពន្យារពេលហួសហេតុ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៧ កថាខណ្ឌ ២៥ ("ការវាយតម្លៃថាតើ សិទ្ធិរបស់ជនជាប់ចោទក្នុងការជំនុំជម្រះដោយមិនមានការពន្យារពេលហួសហេតុ ត្រូវបានរំលោភបំពានឬយ៉ាងណា នឹងត្រូវធ្វើឡើងនៅត្រឹមកាលបរិច្ឆេទថ្ងៃនេះតែប៉ុណ្ណោះ។ ការណ៍នេះមានន័យថា អង្គជំនុំជម្រះ នៅកាលបរិច្ឆេទចុះហត្ថលេខាលើសេចក្តីសម្រេច នឹងធ្វើការកំណត់ថាតើសិទ្ធិរបស់ជនជាប់ចោទក្នុងការជំនុំជម្រះដោយគ្មានការពន្យារពេលហួសហេតុ ត្រូវបានរំលោភ ឬអត់ *មកទល់កាលបរិច្ឆេទនោះ*។ អង្គជំនុំជម្រះនឹងមិនធ្វើការទាយស្មានណាមួយអំពីថាតើ - នៅកាលបរិច្ឆេទនៃសាលក្រម ឬនៅកាលបរិច្ឆេទនៃបណ្តឹងសាទុក្ខពីសាលក្រមស្ថាពរ ប្រសិនបើមាន - សិទ្ធិរបស់ជនជាប់ចោទក្នុងការជំនុំជម្រះដោយគ្មានការពន្យារពេលហួសហេតុ នឹងត្រូវបានរំលោភ ឬទេ។ អង្គជំនុំជម្រះនេះត្រូវបានផ្តល់អំណាចឲ្យតែដើម្បីកំណត់ថាតើ មានការរំលោភបំពានណាមួយលើសិទ្ធិរបស់ជនជាប់ចោទនៅត្រឹមកាលបរិច្ឆេទបច្ចុប្បន្នតែប៉ុណ្ណោះ"។ (គូសបញ្ជាក់បន្ថែម)) ២៦ ("ឯកសារសំអាង [ផ្លូវច្បាប់] ដែលជាចំណោទនេះ គ្រាន់តែតម្រូវឲ្យស្ថាប័នតុលាការ ធ្វើការពិចារណាលើភាពរួមនៃកិច្ចដំណើរការនីតិវិធី *ដែលបានកើតឡើង* នៅពេលដែលខ្លួនធ្វើការវាយតម្លៃរបស់ខ្លួនតែប៉ុណ្ណោះ។ ឧទាហរណ៍ ប្រសិនបើកិច្ចដំណើការនីតិវិធីស្ថិតនៅក្នុងដំណាក់កាលមុនការជំនុំជម្រះ ស្ថាប័នតុលាការត្រូវកំណត់ថាតើ មានការពន្យារពេលហួសហេតុឬទេ មកទល់ពេលនោះ" (គូសបញ្ជាក់បន្ថែម))។

[81] *ផ្ទុយពី* ឯកសារ **D272** សំណើ សុំបញ្ចប់ កថាខណ្ឌ កថាខណ្ឌ ៥៦-៥៩។

[82] ឯកសារ **D272** សំណើ សុំបញ្ចប់ កថាខណ្ឌ ៥៦-៥៨។

នោះក៏គ្មានមូលដ្ឋាននៅក្នុងច្បាប់ផងដែរ។ ពួកវាមើលរំលងយុត្តិសាស្ត្ររបស់ អ.ជ.ត.ក[83] ដែលត្រូវបានទទួលស្គាល់ម្តងហើយម្តងទៀតដោយ អ.ជ.ស.ដ[84] ដែលថាបញ្ហានេះមិនមែនជាបញ្ហាយុត្តាធិការនោះទេ[85]។ ប៉ុន្តែ វាជា "សេចក្តីសម្រេចផ្នែកគោលការណ៍ណែនាំ*តែមួយគត់*" នៅក្នុងឆន្ទានុសិទ្ធិទាំងស្រុងរបស់សហព្រះរាជអាជ្ញា និង ស.ច.ស[86] ហើយ អ.ជ.ស.ដ មិន "ចាប់ផ្តើមការ វាយតម្លៃណាមួយឡើយ" លើបញ្ហានេះ[87]។ បញ្ហាយុត្តាធិការពិតប្រាកដតែមួយគត់ ដែល អ.ជ.ស.ដ ត្រូវតែបញ្ជាក់នោះគឺ មាស មុត គឺជាមន្ត្រីខ្មែរក្រហម[88] ដែលជាអ្វីដែលគាត់មិនដែលបដិសេធ។ អវត្តមានការរកឃើញអំពី"ពុំសុទ្ធចិត្ត និងមិនស្របទៅតាមការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈត្រឹមត្រូវ"របស់ ស.ច.ស.អ ក្នុងការចាប់ផ្តើមឲ្យមានអំណាចពិនិត្យឡើងវិញ "តិចតួចបំផុត"របស់ អ.ជ.ស.ដ[89] នោះ បញ្ហានេះមិនយុត្តិធម៌ទេ។

16. មាស មុត មើលរំលងរឿងក្តីអន្តរជាតិប្រហាក់ប្រហែលគ្នានេះស្តីពី "ការពន្យារពេលហួសហេតុ"។ ទោះបីជាភាពសមហេតុផលនៃរយៈពេលនៃកិច្ចដំណើរការនីតិវិធី ត្រូវវាយតម្លៃលើមូលដ្ឋានមួយដំណាក់កាលម្តងៗយ៉ាងណាក៏ដោយ[90] ក៏ការសិក្សារបស់តុលាការព្រហ្មទណ្ឌអន្តរជាតិបង្ហាញថា កិច្ចដំណើរការនីតិវិធីដែលមានរយៈពេលប្រហាក់ប្រហែលគ្នាទៅនឹងរឿងក្តី ០០៣[91] មិនត្រូវបានគេសន្និដ្ឋានថាត្រូវបានពន្យារពេលហួសហេតុឡើយ ទោះបីជាអង្គហេតុដែលថាជនជាប់ចោទផ្សេងទៀត

---

[83] រឿងក្តី ០០១-**F28** សាលដីកា *ឧុច* កថាខណ្ឌ ៧៩។

[84] រឿងក្តី ០០២-**E465** សាក្រមរឿងក្តី ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ជើងទំព័រ ៣៧។ រឿងក្តី ០០២-**E313** សាលក្រមរឿងក្តី ០០២/០១ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ជើងទំព័រ ៣១។

[85] រឿងក្តី ០០១-**F28** សាលដីកា *ឌុច* កថាខណ្ឌ ៦២-៨១។

[86] រឿងក្តី ០០១-**F28** សាលដីកា *ឌុច* កថាខណ្ឌ ៦៣, ៧៤-៧៥, ៧៧-៧៩, ៨០-៨១ (ដកស្រង់ត្រង់កថាខណ្ឌ ៨០ គូសបញ្ជាក់បន្ថែម)។

[87] រឿងក្តី ០០១-**F28** សាលដីកា *ឌុច* កថាខណ្ឌ ៨១។

[88] រឿងក្តី ០០១-**F28** សាលដីកា *ឌុច* កថាខណ្ឌ ៦១។

[89] រឿងក្តី ០០១-**F28** សាលដីកា *ឌុច* កថាខណ្ឌ ៨០។

[90] *សូមមើលឧទាហរណ៍* ឯកសារ **D120/3/1/8** សេចក្តីពិចារណារបស់ចៅក្រមអន្តរជាតិលើញត្តិរបស់ មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម កថាខណ្ឌ ៣៧។ **ICTR**: សាលដីកា *Nyiramasuhuko* កថាខណ្ឌ ៣៤៦។ សាលដីកា*Renzaho* កថាខណ្ឌ ២៣៨។ សាលដីកា *Nahimana* កថាខណ្ឌ ១០៧៤។

[91] សម្រាប់គោលបំណងប្រៀបធៀបនៃការវិភាគនេះ លើកលែងតែមានការកត់សម្គាល់ផ្សេងពីនេះ រយៈពេលកិច្ចដំណើរការនីតិវិធីតុលាការត្រូវបានគណនាចាប់ពីកាលបរិច្ឆេទដែលជនសង្ស័យត្រូវបានបញ្ជូនទៅតុលាការ មកត្រឹមកាលបរិច្ឆេទសាលក្រមលើបណ្តឹងសាទុក្ខស្ថាពរ។

ស្ថិតក្នុងការឃុំខ្លួន។ ដោយយោងទៅលើអាណត្តិស្រដៀងគ្នារបស់តុលាការទាំងអស់នេះ និងភាពស្មុកស្មាញរបស់វាផ្ទាល់នៃសំណុំរឿងនៅចំពោះមុខពួកខ្លួន "វាមិនមែនមិនសមហេតុផលទេ ក្នុងការរំពឹងថា ដំណើរការតុលាការនឹងមិនតែងតែលឿនដូចតុលាការក្នុងស្រុកជានិច្ចនោះទេ"[92]។ ឧទាហរណ៍ នៅតុលាការ ICTR មិនមានការសន្និដ្ឋានអំពីការពន្យារពេលហួសហេតុឡើយ សម្រាប់កិច្ចដំណើរការនីតិវិធីតុលាការដែលមានរយៈពេលប្រហែលប្រាំបី ទៅ ១១ឆ្នាំ សម្រាប់ជនសង្ស័យស្ថិតក្នុងមន្ទីរឃុំឃាំង ដែលប្រឈមមុខបទចោទចំនួនប្រាំ ឬតិចជាងនេះ ទាក់ទងនឹងអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុង (i) រឿងក្ដីដែលមានជនជាប់ចោទតែម្នាក់ ដែលមានសវនាការជំនុំជម្រះលើភ័ស្តុតាងរយៈពេល ២៨ ថ្ងៃ[93] និង (ii) ក្នុងរឿងក្ដីដែលមានសហជនជាប់ចោទ ដែលត្រៀមសម្រាប់ការជំនុំជម្រះ ដោយមានសវនាការជំនុំជម្រះលើភ័ស្តុតាងរយៈពេល ៣២ថ្ងៃ[94] និង ៨០ថ្ងៃ[95]។ នៅតុលាការ ICC មិនមានការសន្និដ្ឋានអំពីការពន្យារពេលហួសហេតុត្រូវបានធ្វើឡើងនៅក្នុងរឿងក្ដីដែលមានជនជាប់ចោទតែម្នាក់ ដែលជនសង្ស័យស្ថិតក្នុងការឃុំខ្លួនរយៈពេលជាង ៨ឆ្នាំកន្លះ ទាក់ទង

---

[92] សាលដីកា *Nahimana* កថាខណ្ឌ ១០៧៦។ *សូមមើលផងដែរ* សាលក្រម *Ayyash និងគូកន* កថាខណ្ឌ ៩៦៦។

[93] កិច្ចដំណើរការនីតិវិធីតុលាការមានរយៈពេលប្រហែលជា ៨ឆ្នាំ (ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៤ ដល់ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១២)៖ *Kanyarukiga*, ICTR-2002-78-T, សាលក្រម និងការកំណត់ទោស ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១០ កថាខណ្ឌ ២ និង ឧបសម្ព័ន្ធ ក កថាខណ្ឌ ៦៩១-៦៩៣ (ត្រូវបានបញ្ជូននៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៤ បទចោទចំនួន ៤។ ការជំនុំជម្រះ៖ ស្ដាប់សវនាការសាក្សីចំនួន ៣៤នាក់ ក្នុងរយៈពេល ២៨ថ្ងៃ)។ *Kanyarukiga*, ICTR-02-78-A, សាលក្រម ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១២ កថាខណ្ឌ ២៨៥ (ផ្នែកសម្រេចសេចក្ដី)។

[94] កិច្ចដំណើរការនីតិវិធីតុលាការមានរយៈពេលជាង ៩ឆ្នាំ (ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៣ ដល់ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១២)៖ *Hategekimana*, ICTR-00-55B-T, សាលក្រម និង ការកំណត់ទោស ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១០ កថាខណ្ឌ ៧ និងឧបសម្ព័ន្ធ ក កថាខណ្ឌ ៥, ៨ (ត្រូវបានបញ្ជូននៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៣ បំបែកកិច្ចដំណើរការនីតិវិធីចេញពីសហជនជាប់ចោទ នៅថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៧។ មាន ៤ បទចោទ។ សវនាការជំនុំជម្រះ៖ ស្ដាប់សវនាការសាក្សីចំនួន ៤០នាក់ ក្នុងរយៈពេលជាង ៤៣ថ្ងៃ)។ *Hategekimana*, ICTR-00-55B-A, សាលក្រម ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១២ កថាខណ្ឌ ៣០៧ (ផ្នែកសម្រេចសេចក្ដី)។

[95] កិច្ចដំណើរការនីតិវិធីតុលាការមានរយៈពេលប្រហែល ១០,៥ ឆ្នាំ (ពីថ្ងៃទី៣០ខែតុលា ឆ្នាំ២០០០ ដល់ថ្ងៃទី១ ខែមេសា ឆ្នាំ២០១១)៖ *Muvunyi*, ICTR-2000-55A-T, សាលក្រម និងការកំណត់ទោស ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៦ កថាខណ្ឌ ៥-៦ និងឧបសម្ព័ន្ធ I កថាខណ្ឌ ១៥ (ត្រូវបានបញ្ជូននៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០០។ ត្រូវបានបំបែកកិច្ចដំណើរការនីតិវិធីចេញពីសហជនជាប់ចោទនៅថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០០៣។ មាន ៥ បទចោទ។ ការជំនុំជម្រះបឋម៖ ស្ដាប់សវនាការសាក្សីចំនួប ៤៨នាក់ ក្នុងរយៈពេលជាង ៨០ថ្ងៃ)។ *Muvunyi*, ICTR-2000-55A-A, សាលដីកា ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០១១ (សាលក្រមស្ដាពរ ថ្ងៃទី១ ខែមេសា ឆ្នាំ២០១១) ផ្នែកសម្រេចសេចក្ដី។

ទៅនឹងបទចោទប្រកាន់ចំនួនពីរ អំពីឧក្រិដ្ឋកម្មសង្គ្រាម និងមានសវនាការជំនុំជម្រះចំននួន ២០៤ថ្ងៃ[96]។ នៅតុលាការ SCSL ក៏មិនមានការសន្និដ្ឋានការពន្យារពេលហួសហេតុនៅក្នុងរឿងក្តីដែលមានជនជាប់ចោទតែម្នាក់ផងដែរ ដែលមានរយៈពេលលើសពី ១០ឆ្នាំ ដែលជនសង្ស័យបានចំណាយពេល ៧ឆ្នាំកន្លះនៅក្នុងមន្ទីរឃុំឃាំង សម្រាប់បទចោទប្រកាន់ចំនួន ១១ នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម និងមានសវនាការជំនុំជម្រះលើភ័ស្តុតាងចំនួន ៤២០ថ្ងៃ[97]។ នៅតុលាការ ICTY ក្នុងរឿងក្តីដែលមានជនជាប់ចោទតែម្នាក់ និងបទចោទប្រកាន់ចំនួនប្រាំបួន អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម មានរយៈពេល*ជាង* ១៣ឆ្នាំ សម្រាប់ជនសង្ស័យម្នាក់ ដែលស្ថិតក្នុងមន្ទីរឃុំឃាំងរហូតទាល់តែគាត់ត្រូវបានព្យាបាលនៅមន្ទីរពេទ្យ[98]។ រយៈពេលនៃកិច្ចដំណើរការនីតិវិធីទាំងនោះមិន

---

[96] កិច្ចដំណើរការនីតិវិធីតុលាការមានរយៈពេលជាង ៨,៥ ឆ្នាំ (ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៦ ដល់ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៤)៖ *Lubanga*, ICC-01/04-01/06-2901, សេចក្តីសម្រេចលើការកំណត់ទោសអនុលោមតាមមាត្រា ៧៦ នៃលក្ខន្តិកៈ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១២ (កថាខណ្ឌ ១០៤ (ត្រូវបានបញ្ជូននៅថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០០៦)។ *Lubanga*, ICC-01/04-01/06-2842, សាលក្រមអនុលោមតាមមាត្រា ៧៤ នៃលក្ខន្តិកៈ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១២ កថាខណ្ឌ ១, ១១, (២ បទចោទ។ សវនាការជំនុំជម្រះ៖ សាក្សី ៦៧នាក់ និង ថ្ងៃសវនាការចំនួន ២០៤ថ្ងៃ)។ *Lubanga*, ICC-01/04-01/06-3121-Red, សាលក្រមលើបណ្តឹងសាទុក្ខរបស់លោក Thomas Lubanga Dyilo ប្រឆាំងនឹងការផ្តន្ទាទោសគាត់ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៤ កថាខណ្ឌ ១៥៩។

[97] ដោយសារតែ Taylor មានការជូនដំណឹងអំពីដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំងនឹងគាត់នៅត្រឹមពេលដែលការិយាល័យ SCSL របស់រដ្ឋអាជ្ញាធ្វើវាឱ្យទៅជាសាធារណៈ រយៈពេលនៃកិច្ចដំណើរការនីតិវិធីតុលាការ ត្រូវបានគណៈនាចាប់ពីកាលបរិច្ឆេទដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានបកត្រា និងដីកាបង្គាប់ឱ្យនាំខ្លួនត្រូវបានចេញមកទលកាលបរិច្ឆេទនៃសាលដីកាបណ្តឹងសាទុក្ខ។ ការប្រើការគណនានេះ កិច្ចដំណើរការនីតិវិធីតុលាការប្រឆាំងនឹង Taylor មានរយៈពេលជាង ១០ឆ្នាំ (ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០០៣ ដល់ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣) ដោយគាត់ស្ថិតក្នុងមន្ទីរឃុំឃាំងចាប់ពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៦។ *Taylor,* SCSL-03-01-T-1283, សាលក្រម ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១២ កថាខណ្ឌ ៩-១០ និងឧបសម្ពន្ធ ខ កថាខណ្ឌ ១៩ (សាលក្រមត្រូវបានបកត្រា និងដីកាបង្គាប់ឱ្យនាំខ្លួនត្រូវបានចេញនៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០០៣។ ត្រូវបានបញ្ជូននៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៦។ មាន ១១ បទចោទ។ សវនាការជំនុំជម្រះ៖ សាក្សី ១១៥ ត្រូវបានស្តាប់សវនាការ ក្នុងរយៈពេលជាំង ៤២០ថ្ងៃ)។ SCSL-03-01-A-1389, សាលក្រម ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣ ផ្នែកសម្រេចសេចក្តី។

[98] នៅទីនេះ រយៈពេលនៃកិច្ចដំណើរការនីតិវិធីតុលាការត្រូវបានគណនាចាប់ពីកាលបរិច្ឆេទដែលជនសង្ស័យប្រគល់ខ្លួនឱ្យតុលាការ មកទល់ពេលផុតកំណត់នៃកាលបរិច្ឆេទកំណត់ដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម។ *Šešelj*, IT-03-67-T, សាលក្រម ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ ("សាលក្រម *Šešelj*"), វ៉ុល ១ កថាខណ្ឌ ៨ និងឧបសម្ពន្ធ ២ កថាខណ្ឌ ២, ៧៦-៨៦ (បានប្រគល់ខ្លួននៅថ្ងៃទី២៤ខែកុម្ភៈ ឆ្នាំ២០០៣។ មាន៩បទចោទត្រូវបានព្យាបាលនៅមន្ទីរពេទ្យនៅថ្ងៃទី៦ ខែមករា ឆ្នាំ២០១២)។

រាប់បញ្ចូលដំណាក់កាលបណ្ដឹងសាទុក្ខឡើយ[99] និងបានរួមបញ្ចូល -ពីរដង- ការសន្និដ្ឋានថាមិនមានការពន្យារពេលហួសហេតុ[100]។

*ការបញ្ចប់ ការបោះត្រា និងការដាក់បញ្ចូលរឿងក្ដី ០០៣ ក្នុងបណ្ណសារ គឺមិនត្រឹមត្រូវទេ*

17. មាស មុត បានសន្និដ្ឋានមិនត្រឹមត្រូវថា ការរំលោភនីតិវិធីដែលបានចោទប្រកាន់[101] តម្រូវឱ្យបញ្ចប់កិច្ចដំណើរការនីតិវិធី[102]។ វាច្បាស់ណាស់ថាគាត់បានទាញយកទ្រឹស្ដី "រំលោភនីតិវិធី" មកប្រើដោយហេតុថាគាត់ដឹងថា ក្របខណ្ឌច្បាប់ អ.វ.ត.ក មិនអនុញ្ញាតឱ្យមានការបញ្ចប់ (ឬការផ្អាកជាអចិន្ត្រៃយ៍) នៃកិច្ចដំណើរការនីតិវិធីផ្អែកលើមូលដ្ឋានជាធរមានណាមួយផ្សេងទៀតឡើយ ដោយហេតុថា មូលដ្ឋានជាក់លាក់សម្រាប់ការកបញ្ចប់ ដែលមានចែងក្នុងមាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា៖ មរណភាពរបស់ជនជាប់ចោទ ការផុតអាជ្ញាយុកាល ការទទួលបានការលើកលែងទោស និរាករណ៍នៃច្បាប់ និងអាជ្ញាអស់ជំនុំ[103] មិនអាចអនុវត្តបាននៅទីនេះទេ[104]។ យុត្តិសាស្ត្រ អ.ជ.ត.ក និង អ.ជ.ស.ដ បញ្ជាក់ច្បាស់ថា បើមិនមានការរកឃើញអំពីការរំលោភនីតិវិធីទេនោះ កិច្ចដំណើរការនីតិវិធីអាចមិនត្រូវបញ្ចប់ឡើយ លើកលែងតែលើអង្គសេចក្ដី មិនមែនសម្រាប់មូលហេតុជាក់លាក់ទាំងអស់នេះទេ[105]។

---

[99] បន្ទាប់ពីស្ដាប់សវនាការសាក្សី ៩៩នាក់ ក្នុងរយៈពេលជាង ៦៥២ ម៉ោង និង ៤៦ នាទីមក (៧ វិច្ឆិកា ឆ្នាំ២០០៧ ដល់ ១១ កុម្ភៈ ឆ្នាំ២០០៩) បន្តវិញនៅថ្ងៃទី១២ ខែមករា ឆ្នាំ២០១០ ដល់ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១០) ជនសង្ស័យត្រូវបានកាត់ឱ្យរួចទោសពីបទចោទទាំងអស់នៅពេលជំនុំជម្រះ និងមិនមានបណ្ដឹងសាទុក្ខត្រូវបានដាក់ឡើយ។ *សូមមើល* សាលក្រម *Šešelj* វ៉ុល១ ផ្នែកសម្រេចសេចក្ដី ឧបសម្ពន្ធ ២ កថាខណ្ឌ ៤-៦។

[100] *សូមមើល Šešelj*, IT-03-67-T, សេចក្ដីសម្រេចលើញត្តិដាក់ដោយជនជាប់ចោទស្នើសុំឱ្យផ្អាកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១១ កថាខណ្ឌ ២-៣, ៣១។ សេចក្ដីសម្រេចស្ដីពីការរំលោភនីតិវិធីក្នុងរឿងក្ដី *Šešelj* កថាណ្ឌ ៣០។

[101] **D272** សំណើ សុំបញ្ចប់ កថាខណ្ឌ ៦០-៦១, ៦៣, ៦៧។

[102] **D272** សំណើ សុំបញ្ចប់ កថាខណ្ឌ ៤៧, ៦០, ៦៧, ៦៩, ៧៣ ទំព័រ ១, ៣០។

[103] *សូមមើលផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង ("FCCP") មាត្រា ៦។

[104] *សូមមើលផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៨ ដែលចែងអំពីមូលហេតុបន្ថែមនៃការរលត់បណ្ដឹងអាជ្ញាក្នុងកាលៈទេសៈជាក់លាក់ - មិនមានត្រង់ណាអនុវត្តនៅទីនេះទេ - ដែលពួកវាចែងយ៉ាងច្បាស់នៅក្នុងច្បាប់ដាច់ដោយឡែក។

[105] រឿងក្ដី ០០២-**E138/1/10/1/5/7** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ ("សេចក្ដីសម្រេច អ.ជ.ត.ក លើសំណើសុំដោះលែងភ្លាមៗលើកទីពីរ") កថាខណ្ឌ ៣៨។ រឿងក្ដី ០០២-**E116** សេចក្ដីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារ E51/3, E82, E88 និង E92) ចុះថ្ងៃទី៩

18. មាស មុត ខកខានមិនបានគោរពតាមឲ្យបានត្រឹមត្រូវ ឬបំពេញតាមបទដ្ឋាននៃការរំលោភនីតិវិធី "ដ៏ខ្ពស់"[106] នោះទេ។ ដូចដែលគាត់ទទួលស្គាល់[107] ទ្រឹស្តីនេះមានអថិភាព "ដើម្បីធានាថាការរំលោភបំពាន*ធ្ងន់ធ្ងរ*នានាលើកិច្ច ឬលើនីតិវិធី ដែល*មិនត្រឹមត្រូវ ឬខុសច្បាប់ទាំងស្រុងនោះ* មិនត្រូវបានអនុញ្ញាតឲ្យមាន ដើម្បីលុបចោលនូវសិទ្ធិទទួលបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌" ដែលផ្តល់ឲ្យជនជាប់ចោទនៅចំពោះមុខតុលាការមួយ[108]។ ការបញ្ចប់កិច្ចដំណើការនីតិវិធីគឺជា "ដំណោះស្រាយដ៏កំហ៊ុក" ដែលត្រូវប្រើក្នុង "កាលៈទេសៈពិសេស"[109] ដែលចាំបាច់តែនៅពេលណាដែលវា "អាក្រក់" ឬ "ផ្ទុយទៅនឹង" រដ្ឋបាលតុលាការ ក្នុងការអនុញ្ញាតឲ្យកិច្ចដំណើរការនីតិវិធីបន្ត ឬនៅពេលដែលសិទ្ធិរបស់ជនជាប់ចោទត្រូវបានរំលោភ ក្នុងកម្រិតមួយដែលការជំនុំជម្រះត្រឹមត្រូវយុត្តិធម៌មិនអាចធ្វើ

---

ខែកញ្ញា ឆ្នាំ២០១១ កថាខណ្ឌ ១៦-១៧។ ផ្ទុយទៅនឹងសារណារបស់ មាស មុត (**D272** សំណើ សុំបញ្ចប់ កថាខណ្ឌ ៦៤) ការដាក់ឲ្យ "ផ្អាក" តែមួយគត់ក្រោមច្បាប់កម្ពុជាគឺជាការផ្អាកបណ្តោះអាសន្ន ឬមានលក្ខខណ្ឌ (រឿងក្តី ០០២-**E138/1/10/1/5/7** សេចក្តីសម្រេច អ.ជ.ត.ក លើសំណើសុំដោះលែងភ្លាមៗលើកទីពីរ កថាខណ្ឌ ៣៦, ៣៨) ដែលនឹងត្រូវលុបចោលវិញនៅពេលដែលឧបស័គ្គរាំងកិច្ចដំណើរការនីតិវិធីត្រូវបានដកចេញ (រឿងក្តី ០០២-**E138/1/10/1/5/7** សេចក្តីសម្រេច អ.ជ.ត.ក លើសំណើសុំដោះលែងភ្លាមៗលើកទីពីរ កថាខណ្ឌ ៣៨។ រឿងក្តី ០០២-**E138/1/7** សេចក្តីសម្រេចលើបណ្តឹងសារទុក្ខភ្លាមៗ ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ កថាខណ្ឌ ១៧)។

[106] រឿងក្តី០០២-**D264/2/6** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹង ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបដិសេធសំណើសុំផ្អាកកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធី (D264/1) ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ស្តីពីការរំលោភនីតិវិធី") កថាខណ្ឌ ២៤ *ដកស្រង់* សេចក្តីសម្រេចស្តីពីការរំលោភនីតិវិធីក្នុងរឿងក្តី *Šešelj* កថាខណ្ឌ ២២។

[107] **D272** សំណើ សុំបញ្ចប់ កថាខណ្ឌ ៦៣។

[108] រឿងក្តី០០២-**D264/2/6** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ស្តីពីការរំលោភនីតិវិធី កថាខណ្ឌ ១០ (គូសបញ្ជាក់បន្ថែម) *ដកស្រង់ Barayagwiza*, ICTR-97-19-AR72, សេចក្តីសម្រេច ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ១៩៩៩ កថាខណ្ឌ ៤។

[109] *Lubanga*, ICC-01/04-01/06-2690-Red2, សេចក្តីសម្រេចកោសលុបស្តីពី "ពាក្យសុំរបស់មេធាវីការពារក្តីសុំឲ្យផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍" ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១១ ("សេចក្តីសម្រេចលើការផ្អាកចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១១ ក្នុងរឿងក្តី *Lubanga*") កថាខណ្ឌ ១៦៥ *ដកស្រង់ Lubanga*, ICC-01/04-01/06-2582, សាលក្រមលើបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង I ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១០ មានចំណងជើងថា "សេចក្តីសម្រេចលើសំណើបន្ទាន់របស់អយ្យការ សុំឲ្យមានជម្រើសផ្សេងសម្រាប់ពេលវេលាកំណត់ដាក់បង្ហាញអត្តសញ្ញាណរបស់អន្តរការី ១៤៣ ឬម្យ៉ាងវិញទៀតសុំឲ្យផ្អាកកិច្ចដំណើរការនីតិវិធី រង់ចាំការពិគ្រោះយោបល់បន្ថែមទៀតជាមួយ VWU" ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១០ កថាខណ្ឌ ៥៥។ *Karemera និងគូកន.*, ICTR-98-44-T, សេចក្តីសម្រេចលើញត្តិរបស់ Édouard Karemera ទាក់ទងទៅនឹងសិទ្ធិរបស់គាត់ក្នុងការជំនុំជម្រះដោយគ្មានការពន្យារពេលហួសហេតុ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩ ("សេចក្តីសម្រេចស្តីពីការពន្យារពេលក្នុងរឿងក្តី *Karemera*") កថាខណ្ឌ ៦។

ទៅបាន[110]។ អ.វ.ត.ក និងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត បានបញ្ជាក់យ៉ាងច្បាស់លាស់ថា *មានតែ*ក្នុងករណីដែលជនត្រូវចោទបានទទួលរងការធ្វើបាបធ្ងន់ធ្ងរ ដូចជា ការប្រព្រឹត្តិបែបអមនុស្សធម៌ ឃោរឃៅ ឬបន្ទាបបន្ថោក ឬការធ្វើទារុណកម្ម ឬក្នុងករណីដែលមានការរំលោភបំពាន*ជាក់ស្តែង* លើសិទ្ធិរបស់គាត់ ទើបការធ្វើតេស្តិ៍នេះអាចបំពេញបាន[111]។

19. មាស មុត មើលរំលងថា ការបញ្ចប់កិច្ចដំណើរការនិតិវិធីនឹង "ជាធម្មតាមិនសមមាត្រ" ទៅនឹងព្យសនកម្មដែលទទួលរង[112]។ អង្គជំនុំជម្រះនេះបានសម្រេចពីមុនមកថា ក្នុងការរៀបចំឱ្យមានដំណោះស្រាយសមស្រប តុល្យភាពត្រឹមត្រូវ ត្រូវតែរក្សាឱ្យបានរវាង សិទ្ធិរបស់ជនជាប់ចោទ និងផលប្រយោជន៍ជាសារវន្តរបស់កម្ពុជា និងសហគមអន្តរជាតិ ក្នុងការកាត់ទោសបុគ្គល ដែលត្រូវបានចោទប្រកាន់ដោយឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរបំផុត[113] ដើម្បីលើកកម្ពស់ការផ្សះផ្សាបង្រួបបង្រួម

---

[110] *សូមមើលឧទាហរណ៍* សេចក្តីសម្រេចស្តីពីការផ្អាកចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១១ ក្នុងរឿងក្តី *Lubanga* កថាខណ្ឌ ២០៣។ *Ntaganda*, ICC-01/04-02/06-1883, សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីស្នើសុំឱ្យផ្អាកកិច្ចដំណើរការនីតិវិធីដោយមានព្យសនកម្មដល់ភាគីអយ្យការ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ កថាខណ្ឌ ២០។ *Kenyatta*, ICC-01/09-02/11-868-Red, សំណៅកោសលុបសាធារណៈ នៃសេចក្តីសម្រេចលើពាក្យសុំរបស់មេធាវីការពារក្តីសុំឱ្យផ្អាកជាអចិន្ត្រៃយ៍នៃកិច្ចដំណើរការនីតិវិធី ដោយយោងទៅលើការរំលោភនីតិវិធី ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៣ កថាខណ្ឌ ១៤។ *សូមមើលផងដែរ* *Kallon & Kamara,* SCSL-2004-15-AR72(E) & SCSL-2004-16-AR72(E), សេចក្តីសម្រេចលើការជំទាស់នឹងយុត្តាធិការ៖ Lomé Accord Amnesty, ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៤ កថាខណ្ឌ ៧៩។

[111] រឿងក្តី ០០២-**D264/2/6** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ស្តីពីការរំលោភនីតិវិធី កថាខណ្ឌ ២៧។ *Dragan Nikolić*, IT-94-2-PT, សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីជំទាស់ទៅនឹងការអនុវត្តយុត្តាធិការដោយអង្គជំនុំជម្រះ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០២ កថាខណ្ឌ ១១៤។ *Lubanga*, ICC-01/04-01/06-772, សាលក្រមលើបណ្តឹងឧទ្ធរណ៍របស់លោក Thomas Lubanga Dyilo ប្រឆាំងនឹងសេចក្តីសម្រេចលើការជំទាស់របស់មេធាវីការពារក្តីទៅនឹងយុត្តាធិការរបស់តុលាការអនុលោមតាមមាត្រា ១៩(២)(ក) នៃលក្ខន្តិកៈថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៦ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦ កថាខណ្ឌ ៣១។ *Dragan Nikolić*, IT-94-2-AR73, សេចក្តីសម្រេចបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំទាក់ទងនឹងនីត្យានុកូលភាពនៃការចាប់ខ្លួន ចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៣ ("សេចក្តីសម្រេចស្តីពីនីត្យានុកូលភាពក្នុងរឿងក្តី *Nikolić*") កថាខណ្ឌ ២, ២៨-៣៣។ *Barayagwiza*, ICTR-97-19-AR72, សេចក្តីសម្រេច ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ១៩៩៩ កថាខណ្ឌ ៧៥។

[112] *Nikolić* សេចក្តីសម្រេចស្តីពីនីត្យានុកូលភាព កថាខណ្ឌ ៣០ *អនុវត្តតាមដោយ* រឿងក្តី ០០២-**D264/2/6** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ស្តីពីការរំលោភនីតិវិធី ជើងទំព័រ ៥២។ *Kajelijeli*, ICTR-98-44A-A, សាលដីកា ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៥ ("សាលដីកា *Kajelijeli*") កថាខណ្ឌ ២០៦។ *សូមមើលផងដែរ* សេចក្តីសម្រេចស្តីពីការពន្យារពេលហួសហេតុ កថាខណ្ឌ ៤, ៦។

[113] រឿងក្តី ០០២-**D264/2/6** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបដិសេធសំណើសុំផ្អាកកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធី (D264/1) កថាខណ្ឌ ២៨។ ចំណុចនេះ

ជាតិ ដោយការធានាថា ជនរងគ្រោះនៃឧក្រិដ្ឋកម្មមានសំឡេងប្រកបដោយអត្ថន័យ[114]។ តាមពិត វិធាន ២១(១) នៃវិធានផ្ទៃក្នុងតម្រូវថា ច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង ត្រូវតែបកស្រាយក្នុងន័យការពារផលប្រយោជន៍របស់ជនជាប់ចោទ *ក៏ដូចជា*ជនរងគ្រោះ[115]។ វាបានកំណត់បន្ថែមទៀតថា កិច្ចដំណើរការនីតិវិធី "ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ"[116]។ តម្រូវការឲ្យមានតុល្យភាពនៃសិទ្ធិរបស់ភាគី *ទាំងអស់* - រួមទាំងជនរងគ្រោះ និងភាគីចោទប្រកាន់ ដែលបំពេញកិច្ចតំណាងឲ្យ និងក្នុងផលប្រយោជន៍សង្គមកម្ពុជា

---

មានលក្ខណៈច្បាស់លាស់ជាពិសេសក្នុងការអះអាងអំពីរំលោភនីតិវិធី ដែលបានលើកឡើងនៅតុលាការ ICTY, ICTR និង ICC។ *សូមមើលឧទាហរណ៍* សេចក្ដីសម្រេចស្ដីពីនីត្យានុកូលភាពក្នុងរឿងក្ដី *Nikolić* កថាខណ្ឌ ២៤ ("ក្នុងករណីឧក្រិដ្ឋកម្មដូចជាអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ដែលត្រូវបានទទួលស្គាល់ និងថ្កោលទោសជាអន្តរជាតិបែបដូច្នេះ [...] តុលាការហាក់ដូចជារកឃើញនៅក្នុងលក្ខណៈពិសេសនៃបទល្មើសទាំងអស់នេះ និងជាក់ស្ដែងនៅក្នុងភាពធ្ងន់ធ្ងររបស់ពួកវា នូវមូលហេតុសមស្របក្នុងការមិនដកចេញពីយុត្តាធិការ") ២៥-២៦, ៣០ ("ដូច្នេះ តុល្យភាពត្រឹមត្រូវត្រូវតែរក្សារវាងសិទ្ធិជាសារវន្តរបស់ជនជាប់ចោទ និងផលប្រយោជន៍សំខាន់ៗរបស់សហគមអន្តរជាតិ ក្នុងការកាត់ទោសបុគ្គលដែលត្រូវបានចោទដោយការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ")។ *Karadžić*, IT-95-5/18-AR73.4, សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខប្រឆាំងនឹងសេចក្ដីរបស់អង្គជំនុំជម្រះលើកិច្ចព្រមព្រៀង Holbrooke ដែលបានចោទប្រកាន់ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ កថាខណ្ឌ ៤៩, ៥២-៥៣ (បានរំលឹកថា "គោលបំណងជាសារវន្តមួយនៃតុលាការ និងសាលាក្ដីអន្តរជាតិ គឺត្រូវបញ្ចប់និទណ្ឌភាព និងត្រូវធានាថា ការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ត្រូវបានផ្ដន្ទាទោស និងដាក់ទណ្ឌកម្ម" ហើយអង្គហេតុដែលនាំឲ្យមានការរំពឹងទុករបស់ម្ចាស់បណ្ដឹងសាទុក្ខអំពីនិទណ្ឌភាព ទោះបីជាត្រូវបានបញ្ជាក់ ក៏មិននាំឲ្យមានការចាប់ប្រើការរំលោភនីតិវិធី ដែលផ្ដល់យុត្តិកម្មដល់ការផ្អាកកិច្ចដំណើរការនីតិវិធីដែរ)។ *សូមមើលផងដែរ* សាលដីកា *Kajelijeli* កថាខណ្ឌ ២០៦។ សេចក្ដីសម្រេចស្ដីពីការពន្យារពេលហួសហេតុក្នុងរឿងក្ដី *Karemera* កថាខណ្ឌ ៨, ១១។ ការអនុវត្តតាមវិធីសាស្ត្រនេះនឹងផ្ដល់នូវទម្ងន់ដ៏ច្រើនចំពោះគោលបំណង/ផលប្រយោជន៍សំខាន់របស់ អ.វ.ត.ក គឺដើម្បីនាំយកជំនុំជម្រះនូវមេដឹកនាំជាន់ខ្ពស់ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យប្រឆាំងនឹងប្រជាជនកម្ពុជា (*សូមមើល* កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១។ ច្បាប់ អ.វ.ត.ក មាត្រា ១, ២ថ្មី)។

[114] រឿងក្ដី ០០២-**D411/3/6** សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់ សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ("សាលដីការបស់ អជ លើពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី.ប.") កថាខណ្ឌ ៦៤-៦៥។ កិច្ចព្រមព្រៀង អ.វ.ត.ក បុព្វកថា។

[115] វិធាន ២១(១)។ *សូមមើលផងដែរ* មហាសន្និបាតអង្គការសហប្រជាជាតិ សេចក្ដីប្រកាសពីគោលការណ៍មូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគញោះនៃឧក្រិដ្ឋកម្ម និងការរំលោភអំណាច, UNGA Res 40/34 ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ គោលការណ៍លេខ ៤ ("ជនរងគ្រោះគប្បីត្រូវបានប្រព្រឹត្តដោយក្ដីអាណិតអាសូរ និងការគោរពចំពោះសេចក្ដីថ្លៃថ្នូររបស់ពួកគេ។ មានមានសិទ្ធិទទួលបានយុត្តិធម៌និងដំណោះស្រាយឆាប់រហ័ស ដូចមានចែងដោយច្បាប់ជាតិសម្រាប់ព្យសនកម្មដែលពួកគេទទួលរងគ្រោះ")។

[116] វិធាន ២១(១)(ក)។

និងរាល់មនុស្សជាតិទាំងអស់ - ត្រូវបានទទួលស្គាល់នៅក្នុងច្បាប់បារាំង និងកម្ពុជា[117] និងដោយអង្គជំនុំជម្រះនេះ[118] ដោយ អ.ជ.ត.ក[119] និង ដោយសាលាក្តីអន្តរជាតិ[120]។

---

[117] **<u>ប្រទេសបារាំង៖</u>** ក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង article préliminaire; Conseil Constitutionnel, No. 95-360, ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ១៩៩៥ កថាខណ្ឌ ៥។ *សូមមើលផងដែរ* Pradel, *Manuel de Procédure Pénale* (បោះពុម្ពលើកទី ១៤) ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៨ ទំព័រ ១៤១។ **<u>ប្រទេសកម្ពុជា៖</u>** ក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសកម្ពុជា មាត្រា ៤។

[118] រឿងក្តី ០០២-**D411/3/6** សាលដីការបស់ អ.ប.ជ លើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៦៧ ("អង្គបុរេជំនុំជម្រះបកស្រាយវិធានផ្ទៃក្នុង ដោយគិតពិចារណាទៅលើលក្ខណៈ ទំហំ និងទម្រង់នៃការចូលរួម ព្រមទាំងធាតុផ្សំបង្កើតបទល្មើសដែលរងការចោទប្រកាន់ *ព្រមទាំងពីតម្រូវការរបស់សហគមន៍ដែលទទួលរងផលប៉ះពាល់ ដូចមានចែងក្នុងលិខិតុបករណ៍ជាសារវន្តរបស់ អ.វ.ត.ក*") (គូសបញ្ជាក់បន្ថែម))។ រឿងក្តី ០០២-**D404/2/4** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់ សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦៧។

[119] *សូមមើលឧទាហរណ៍* រឿងក្តី ០០២-**F10/2** សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ កថាខណ្ឌ១២។ *សូមមើលផងដែរ* រឿងក្តី ០០២-**E50/2/1/4** សេចក្តីសម្រេចស្តីពីបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងសេចក្តីសម្រេច របស់អង្គជំនុំជម្រះសាលាដំបូង លើសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣៩ (កត់សម្គាល់ថា "គោលការណ៍នៃការបកស្រាយចេញពីវិធាន ២១(១) មិនមានន័យថា វិធានត្រូវតែបកស្រាយក្នុងន័យផ្តល់ប្រយោជន៍ដល់ជនជាប់ចោទដោយស្វ័យប្រវត្តិក្នុងគ្រប់ស្ថានភាពជាក់លាក់ដែលកើតចេញពីការបកស្រាយនៃវិធានផ្ទៃក្នុងឡើយ"។ រឿងក្តី ០០២-**E50/3/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ៣០។

[120] *សូមមើលឧទាហរណ៍ Aleksovski*, IT-95-14/1, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញាលើភាពអាចទទួលយកបាននៃភ័ស្តុតាង ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៩៩ កថាខណ្ឌ ២៥។ *Zigiranyirazo*, ICTR-2001-73-T, សេចក្តីសម្រេចលើញត្តិរបស់រដ្ឋអាជ្ញាសុំឲ្យបើករឿងក្តីរបស់ខ្លួនឡើងវិញ និងធ្វើការសេចក្តីពិចារណាឡើងវិញលើសេចក្តីសម្រេច ថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៦ លើការស្តាប់សវនាការសាក្សី Michel Bagaragaza តាមរយៈការភ្ជាប់វីដេអូតាមអ៊ីនធើណែត ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៦ កថាខណ្ឌ ១៨។ *Karemera និងគូកន*, ICTR-98-44-PT, សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីនៃរឿងក្តី André Rwamakuba និងការធ្វើវិសោធនកម្មដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ ២៦។ *ស្ថានភាពក្នុងសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ* ICC-01/04-135tEN, សេចក្តីសម្រេចលើពាក្យសុំរបស់រដ្ឋអាជ្ញាសុំការអនុញ្ញាតប្តឹងសាទុក្ខសេចក្តីសម្រេចរបស់អង្គជំនុំជម្រះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៦ លើពាក្យសុំចូលរួមក្នុងកិច្ចដំណើរការនីតិវិធីរបស់សាក្សី VPRS 1, VPRS 2, VPRS 3, VPRS 4, VPRS 5 និង VPRS 6 ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ ៣៨។ *ស្ថានភាពក្នុងប្រទេសយូហ្គេនដា*,ICC-02/04-112, សេចក្តីសម្រេចលើពាក្យសុំរបស់រដ្ឋអាជ្ញាសុំការអនុញ្ញាតប្តឹងសាទុក្ខលើពាក្យសុំចូលរួមរបស់ជនរងគ្រោះ សម្រាប់ការចូលរួម a/0010/06, a/0064/06 to a/0070/06, a/0081/06 to a/0104/06 និង a/0111/06 ដល់ a/0127/06, ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៧ កថាណ្ឌ២៧។

20. ដូចបានពិភាក្សាខាងលើ មាស មុត ខកខានមិនបានបង្ហាញអំពីការពន្យារពេលហួសហេតុណាមួយនៅក្នុងរឿងក្តី ០០៣ ឡើយ ហើយការដែលគ្រាន់តែទាយស្មានរបស់គាត់អំពី "លទ្ធភាព" [121]*អនាគត*នៃរឿងក្តី ០០៣ មិនអាចគាំទ្រដល់ការអះអាងអំពីការរំលោភនីតិវិធីឡើយ។ ក្នុងករណីណាក៏ដោយ ការបញ្ចប់រឿងក្តី ០០៣ នឹងក្លាយជាដំណោះស្រាយមិនសមាមាត្រខ្លាំងសម្រាប់ការរំលោភបំពានដែលបានចោទប្រកាន់ នៅពេលដែលគាត់ប្រឈមមុខនឹងការចោទប្រកាន់អំពីឧក្រិដ្ឋកម្មដែលមានភាពធ្ងន់ធ្ងរបែបនេះ។ តាមពិត វាដូចជាមិនសមទំនងទាល់តែសោះ ក្នុងការលើកឡើងអំពីព្យសនកម្មដែលចោទប្រកាន់របស់ មាស មុត ដោយសារតែការលើកលែងចោទប្រកាន់ដែលមិនទាក់ទងទៅនឹងអង្គសេចក្តីនៃរឿងក្តី ០០៣ មិនការពារកិត្តិយសរបស់ មាស មុត ឬ អនុញ្ញាតឲ្យគាត់ជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះទេ។ ដំណោះស្រាយដ៏ត្រឹមត្រូវបំផុតចំពោះការខ្វល់ខ្វាយរបស់គាត់អំពីការដែលមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមិនអាចជំទាស់បានតាមលងបន្លាចគាត់ "ជារៀងរហូត"[122] នោះ គឺត្រូវបញ្ជូនរឿងក្តីនេះទៅជំនុំជម្រះ។

## III. សេចក្តីសន្និដ្ឋាន

21. ស.ព.អ យល់ស្របជាមួយ មាស មុត ថា ការជាប់គាំងផ្នែកនីតិវិធី ដែលកើតមានបន្ទាប់ពីការចេញសេចក្តីពិចារណារបស់ អ.ប.ជ មិនត្រូវអនុញ្ញាតឲ្យបន្តទៀតទេ។ វាចាំបាច់ណាស់ថា ដំណាក់កាលមុនការជំនុំជម្រះនៃរឿងក្តី ០០៣ ត្រូវបិទបញ្ចប់*តាមរយៈការកំណត់តាមផ្លូវតុលាការ*។ ទោះជាយ៉ាងណាច្បាស់ណាស់ថា ច្បាប់តម្រូវថា អ.ប.ជ បដិសេធសំណើរបស់ មាស មុត និងបញ្ជូនរឿងក្តីនេះទៅជំនុំជម្រះ ដោយផ្អែកលើក្របខណ្ឌច្បាប់ អ.វ.ត.ក និងការសន្និដ្ឋានជាឯកច្ឆ័ន្ទរបស់ខ្លួនថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព។ វាក៏ច្បាស់ដូចគ្នាផងដែរថា ផលប្រយោជន៍នៃយុត្តិធម៌ក៏តម្រូវឲ្យមានលទ្ធផលដូចគ្នានេះដែរ។

## IV. ដំណោះស្រាយដែលស្នើសុំ

22. សម្រាប់មូលហេតុដូចបានរៀបរាប់ខាងលើ ស.ព.អ ស្នើសុំដោយគោរពឲ្យ អ.ប.ជ៖

ក. បដិសេធសំណើសុំបញ្ចប់។

---

[121] **D272** សំណើ សុំបញ្ចប់ កថាខណ្ឌ ៦២។ *សូមមើលផងដែរ* កថាខណ្ឌ ៦៧។

[122] **D272** សំណើ សុំបញ្ចប់ កថាខណ្ឌ ១៨, ៥៤, ៧១។

ខ. បិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះនៃរឿងក្តី ០០៣ ដោយការផ្តល់ការកំណត់ជាស្ថាពរ ដែលឯកភាពគ្នាមួយ ដែលបញ្ជាក់ថា មាស មុត ត្រូវបានចោទប្រកាន់ និងបង្គាប់ឲ្យនាំខ្លួនគាត់ទៅជំនុំជម្រះ; ហើយនឹង

ខ. ចាត់វាល់វិធានការរដ្ឋបាលដែលចាំបាច់ទាំងអស់ ដើម្បីបញ្ជូនជាបន្ទាន់នូវសេចក្តីពិចារណាដីកាបញ្ជូនរឿងទៅជំនុំជម្រះនៃរឿងក្តី ០០៣ និងសំណុំរឿងដែលនៅសេសសល់ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២១ | **លោកស្រី Brenda J HOLLIS**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |